# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម

១៨-០១-២០០៦ -ព្រះរាជក្រម នស/រកម/០១០៦/00២ ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញា ស្ដីពីការត្រួតពិនិត្យថ្នាំជក់ ៣២៤

### ២_ព្រះរាជក្រឹត្យ

៣០-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៨ ស្ដីពីការតែងតាំងលោក **ជួន មាសចំរើន** ជាឧបការីសម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤១០

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/00៧ ស្ដីពីការតែងតាំងឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត **ត្រឹ ម៉ល់** ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកផ្នែកភាសាវិទ្យា នៅរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤១១

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/00៨ ស្ដីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈជូនសពនាយទាហានជាន់ខ្ពស់ចំនួន ០៣ រូប ៤១២

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/00៩ ស្ដីពីការតែងតាំង :
១-ឯកឧត្តម ឧត្តមសេនីយ៍ឯកចំនួន ២ រូប ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម ឧត្តមសេនីយ៍ត្រីចំនួន ២ រូប ជាជំនួយការផ្ទាល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៤១៣

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០១០ ស្ដីពីការតែងតាំងឯកឧត្តម **សុខ ចិន្តា** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (គ.ស.ព) មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៤១៤

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០១១ ស្ដីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **នូច ណារ៉ុថ** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៤១៥

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០១២ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **កៅ ឡារីជើស៊ុង** (KAO LARRY JERHSIUNG) សញ្ជាតិអាមេរិក ដើមកំណើតចិន កើតនៅកោះតៃវ៉ាន់ ប្រទេសចិន ដោយប្តូរឈ្មោះជា **កៅ វីរៈ** (KAO VIREAK) ៤១៦

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០១៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះមហាឧបាសក **លឹម ឈុន** និង មហាឧបាសិកា **ចាយ គន់** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៤១៧

១៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០១៤ ស្តីពីការប្រោសព្រះរាជទានចំពោះឧបាសិកា **ហ៊ុំ ម៉ុនសេង** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤១៨

## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

១៦-០១-២០០៦ -អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤១៩

១៦-០១-២០០៦ -អនុក្រឹត្យលេខ ២៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤២០

១៦-០១-២០០៦ -អនុក្រឹត្យលេខ ២៩អនក្រ.តតស្តីពីការលុបឈ្មោះនាយទាហាននៃកងយោធពលខេមរភូមិន្ទ ៤២១

១៦-០១-២០០៦ -អនុក្រឹត្យលេខ ៣០ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៤២២

១៦-០១-២០០៦ -អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤២៤

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤២៩

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៣០

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣១

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣២

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៣៣

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣៤

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៥

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៣៦

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣៧

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៨

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៣៩

១៧-០១-២០០៦ -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤១

# ព្រះរាជក្រម

នស/រកម/០១០៦/០០២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករាឆ្នាំ ២០០៦

នស/រកម/០១០៦/០២០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហត្ថលេខា**

**នូត សុខុម**

លេខៈ ៣៧ . ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

អង្គការសុខភាពពិភពលោក
ទីក្រុងហ្សឺណែវ ប្រទេសស្វីស

# អនុសញ្ញារបស់អង្គការសុខភាពពិភពលោក
# ស្តីពី
# ការត្រួតពិនិត្យថ្នាំជក់

អង្គការសុខភាពពិភពលោក
ឆ្នាំ២០០៣

ទិន្នន័យនៃឯកសារផ្សព្វផ្សាយបញ្ចូលក្នុងបញ្ជីរបស់បណ្ណាល័យនៃអង្គការសុខភាពពិភពលោក

អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោក

១- ថ្នាំជក់ ការផ្តល់និងការចែកចាយ ២- ឧស្សាហកម្មថ្នាំជក់ នីតិកម្ម ៣-ការបំពុលនៃផ្សែងថ្នាំជក់ ការបង្ការ និងការត្រួតពិនិត្យ ៤- ការឈប់ប្រើថ្នាំជក់ ៥- សន្ធិសញ្ញា

I. **អង្គការសុខភាពពិភពលោក**

ISBN 92 41591013 (LC/NLM classification: HD 9130.6)

© អង្គការសុខភាពពិភពលោកឆ្នាំ២០០៣ បោះពុម្ពជាថ្មីឡើងវិញ និងផ្តល់ទិន្នន័យថ្មីបំផុតឆ្នាំ២០០៤

រក្សាគ្រប់សិទ្ធិទាំងអស់ ។ ឯកសារបោះពុម្ពផ្សាយដោយអង្គការសុខភាពពិភពលោក អាចទទួលបានអង្គភាពម៉ាកឹធិញនិងការផ្សព្វផ្សាយនៃអង្គការសុខភាពពិភពលោកអាស័យដ្ឋានលេខ ២០ វុត្តវិថី Appia, 1211 ទីក្រុងហ្សឺណែវ ២៧ ប្រទេសស្វីស (ទូរស័ព្ទ: + 41 22 791 2476, ទូរសារ: +41 22 791 4857. Email: bookorders@who.int)

សំណើសុំការអនុញ្ញាតបោះពុម្ពជាថ្មី ឬបកប្រែឯកសារបោះពុម្ពផ្សាយដោយអង្គការសុខភាពពិភពលោក ទោះជាសម្រាប់លក់ ឬសំរាប់ការចែកចាយមិនមែនពាណិជ្ជកម្ម ត្រូវស្នើទៅអង្គភាពបោះពុម្ពផ្សាយនៅអាសយដ្ឋានខាងលើ (ទូរសារ: +41 22 791 4857. Email: bookorders@who.int) ។

ឈ្មោះដែលប្រើ និងការបង្ហាញសម្ភារៈនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ ពុំមានពាក់ព័ន្ធដល់ការសំដែងនូវមតិរបស់អង្គការសុខភាពពិភពលោក ទាក់ទងដល់ឋានៈច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬអាជ្ញាធរណាមួយ ឬទាក់ទងដល់ការកំណត់ព្រំដែនឡើយ ។ ខ្សែបន្ទាត់ដែលគូសនៅលើផែនទី គ្រាន់តែបង្ហាញនូវបន្ទាត់ព្រំដែនប្រហាក់ប្រហែល ហើយក៏ប្រហែលជាពុំទាន់មានការព្រមព្រៀងពេញលេញនៅឡើយ ។

ការនិយាយពីក្រុមហ៊ុនណាមួយ ឬផលិតផលរបស់កម្មន្តសាលណាមួយក៏មិនមែនមានន័យថា អង្គការសុខភាពពិភពលោកបានផ្តល់នូវការគាំទ្រ ឬចូលចិត្តជាងផលិតផលដូចគ្នា ដែលពុំបានលើកយកមកនិយាយនោះទេ ។ លើកលែងតែមានការភ័ន្តច្រឡំ ឬភ្លេចភ្លាំងអក្សរដើមនៃម្ចាស់ផលិតផល ត្រូវបានសរសេរជាអក្សរធំ ។

អង្គការសុខភាពពិភពលោក ពុំធានាថា ព័ត៌មានដែលមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះគ្រប់គ្រាន់ ឬត្រូវឥតខ្ចោះនោះទេ ហើយក៏ពុំត្រូវជាប់បន្ទុកទទួលខុសត្រូវដល់ការខូចខាតដែលបណ្តាលមកពីលទ្ធផលនៃការប្រើប្រាស់វាដែរ ។

បោះពុម្ពនៅអង្គការសុខភាពពិភពលោក ទីក្រុងហ្សឺណែវ ។

# អនុសញ្ញារបស់អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ (ក.អ.ត.ថ)

មាតិកា


**បុព្វកថា** ---------------------------------------------------------------------------- ៤

**អារម្ភកថា** ---------------------------------------------------------------------------- ៦

**ផ្នែកទី ១ : សេចក្តីផ្តើម** ---------------------------------------------------------------- ៨

មាត្រា ១ : ការប្រើពាក្យ ---------------------------------------------------------------- ៨

មាត្រា ២ : ទំនាក់ទំនងរវាងអនុសញ្ញានេះនិងកិច្ចព្រមព្រៀង និងលិខិតតូបករណ៍គតិយុត្តផ្សេងទៀត ------------ ៩

**ផ្នែកទី ២ : គោលដៅ គោលការណ៍ណែនាំ និងកាតព្វកិច្ចទូទៅ** ------------------------------------- ៩

មាត្រា ៣ : គោលដៅ ---------------------------------------------------------------------- ៩

មាត្រា ៤ : គោលការណ៍ណែនាំ --------------------------------------------------------------- ១០

មាត្រា ៥ : កាតព្វកិច្ចទូទៅ ----------------------------------------------------------------- ១១

**ផ្នែកទី ៣ : វិធានការទាក់ទងដល់ការបន្ថយតម្រូវការថ្នាំជក់** ----------------------------------------- ១១

មាត្រា ៦ : តម្លៃ និងវិធានការពន្ធដារ ដើម្បីបន្ថយតម្រូវការថ្នាំជក់ --------------------------------- ១២

មាត្រា ៧ : វិធានការមិនទាក់ទងនឹងតម្លៃដើម្បីបន្ថយតម្រូវការថ្នាំជក់ ------------------------------ ១២

មាត្រា ៨ : ការការពារប្រឆាំងនឹងការរងផ្សែងថ្នាំជក់ ------------------------------------------- ១២

មាត្រា ៩ : បទបញ្ជាចំពោះវត្ថុធាតុដែលមាននៅក្នុងផលិតផលថ្នាំជក់ --------------------------------- ១៣

មាត្រា ១០ : បទបញ្ជាចំពោះការប្រាប់ឱ្យដឹងអំពីផលិតផលថ្នាំជក់ ----------------------------------- ១៣

មាត្រា ១១ : ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់ -------------------------------------- ១៣

មាត្រា ១២ : ការអប់រំ ការផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជន--------------- ១៤

មាត្រា ១៣ : ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ --------------- ១៥

មាត្រា ១៤ : វិធានការបន្ថយការញៀនបារី និងការឈប់ជក់ --------------------------------------- ១៧

**ផ្នែកទី ៤ : វិធានការទាក់ទងដល់ការបន្ថយការផ្គត់ផ្គង់ថ្នាំជក់** -------------------------------------- ១៧

មាត្រា ១៥ : ការធ្វើជំនួញខុសច្បាប់លើផលិតផលថ្នាំជក់ ------------------------------------------ ១៧

មាត្រា ១៦ : ការលក់ទៅឱ្យ ឬដោយអនីតិជន ------------------------------------------------- ១៩

មាត្រា ១៧ : ការផ្តល់ការឧបត្ថម្ភចំពោះសកម្មភាពជំនួសដែលអាចធ្វើអោយរស់បាន -------------------- ២០

**ផ្នែកទី ៥ : ការការពារបរិស្ថាន** -------------------------------------------------------- ២០

មាត្រា ១៨ : ការការពារបរិស្ថាន និងសុខភាពប្រជាជន ------------------------------------------ ២០

**ផ្នែកទី ៦ : បញ្ហាទាក់ទងទៅនឹងការទទួលខុសត្រូវ** ---------------------------------------------- ២១

មាត្រា ១៩ : ការទទួលខុសត្រូវ ------------------------------------------------------------ ២១

**ផ្នែកទី ៧ : សហប្រតិបត្តិការ វិទ្យាសាស្ត្រ បច្ចេកទេស និងគមនាគមន៍ព័ត៌មាន** ---------------------- ២១

មាត្រា២០ : ការស្រាវជ្រាវ ការឃ្លាំមើល និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន ----------------------- ២១

មាត្រា ២១ : ការធ្វើរបាយការណ៍ និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន-------------------------- ២៣

មាត្រា ២២ : សហប្រតិបត្តិការក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស និងច្បាប់ ហើយនិងការផ្តល់នូវឯកទេសពាក់ព័ន្ធ ២៤

**ផ្នែកទី ៨ : ការរៀបចំស្ថាប័ន និងធនធានហិរញ្ញវត្ថុ** ----------------------------------------------- ២៥

មាត្រា ២៣ : សន្និសិទភាគី--------------------------------------------------------------- ២៥

មាត្រា ២៤ : លេខាធិការដ្ឋាន ----------------------------------------------------------- ២៦

មាត្រា ២៥ : ទំនាក់ទំនងរវាងសន្និសិទភាគី និងអង្គការអន្តររដ្ឋាភិបាល ---------------------------- ២៧

មាត្រា ២៦ : ធនធានហិរញ្ញវត្ថុ ---------------------------------------------------------- ២៧

**ផ្នែកទី ៩ : ដំណោះស្រាយវិវាទ**------------------------------------------------------------ ២៨

មាត្រា ២៧ : ដំណោះស្រាយវិវាទ -------------------------------------------------------- ២៨

**ផ្នែកទី ១០ : ការវិវត្តន៍នៃអនុសញ្ញា**-------------------------------------------------------- ២៩

មាត្រា ២៨ : វិសោធនកម្មនៃអនុសញ្ញានេះ ----------------------------------------------------- ២៩

មាត្រា ២៩ : ការអនុម័ត និងវិសោធនកម្មលើឧបសម្ព័ន្ធនៃអនុសញ្ញានេះ --------------------------- ២៩

**ផ្នែកទី ១១ : អវសានប្បញ្ញត្តិ** ---------------------------------------------------------- ៣០

មាត្រា ៣០ : ការរក្សាសិទ្ធិមិនទាន់សំរេច ---------------------------------------------------- ៣០

មាត្រា ៣១ : ការសុំដកខ្លួនចេញ ---------------------------------------------------------- ៣០

មាត្រា ៣២ : សិទ្ធិបោះឆ្នោត--------------------------------------------------------------- ៣០

មាត្រា ៣៣ : សេចក្តីព្រាងពិធីសារ ----------------------------------------------------------- ៣១

មាត្រា ៣៤ : ការចុះហត្ថលេខា ----------------------------------------------------------- ៣១

មាត្រា ៣៥ : ការផ្តល់សច្ចាប័ន ការយល់ព្រម ការបញ្ជាក់ជាផ្លូវការ ឬការសុខចិត្តចូលរួមជាសមាជិក ---------- ៣១

មាត្រា ៣៦ : ការចូលជាធរមាន ---------------------------------------------------------- ៣២

មាត្រា ៣៧ : អ្នកទទួលបញ្ញើ--------------------------------------------------------------- ៣៣

មាត្រា ៣៨ : អត្ថបទយថាភូត ----------------------------------------------------------- ៣៣

**ឧបសម្ព័ន្ធ ១ : WHA លេខ ៥៦ អនុសញ្ញាគោលនៃ WHO ស្តីពីការត្រួតពិនិត្យថ្នាំជក់** ------------------- ៣៤

**ឧបសម្ព័ន្ធ ២ : ប្រវត្តិនៃដំណើរការរបស់អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់** ------------------------------------------------------------ ៣៧

## បុព្វកថា

អនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ ជាសន្ធិសញ្ញាទី១ ដែលត្រូវបានធ្វើការចរចាគ្នានៅក្រោមការឧបត្ថម្ភគាំទ្រនៃអង្គការសុខភាពពិភពលោក ។ អនុសញ្ញានេះ ជាសន្ធិសញ្ញាសំអាងដែលបញ្ជាក់ជាថ្មីនូវសិទ្ធិទទួលបានសុខភាពមានស្តង់ដារខ្ពស់បំផុតរបស់ប្រជាជនទាំងអស់ ។ អនុសញ្ញាជាគំរូនៃការផ្លាស់ប្តូរការអភិវឌ្ឍន៍យុទ្ធសាស្ត្រស្តីពីការដាក់កំរិតលើសារធាតុធ្វើអោយញៀន ។ ផ្ទុយនឹងសន្ធិសញ្ញាស្តីពីការត្រួតពិនិត្យឱសថពីមុនមក អនុសញ្ញាបញ្ជាក់ពីសារសំខាន់នៃយុទ្ធសាស្ត្រ ដើម្បីបន្ថយតម្រូវការ ក៏ដូចជាការផ្គត់ផ្គង់ដែរ ។

អនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ ត្រូវបានអភិវឌ្ឍន៍ដើម្បីឆ្លើយតបទៅនឹងសកលភាវូបនីយកម្មនៃជម្ងឺរាតត្បាតថ្នាំជក់ ។ ការរាលដាលនៃជម្ងឺរាតត្បាតថ្នាំជក់ត្រូវបានសម្រួល ដោយកត្តាដ៏ស្មុគស្មាញច្រើនបែបទាក់ទងដល់ផលប៉ះពាល់ឆ្លងដែន រួមទាំងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ហើយនិងការធ្វើវិនិយោគដោយបរទេសផ្ទាល់ ។ កត្តាផ្សេងទៀតដូចជា ម៉ាកីទិញជាសកល ការផ្សាយពាណិជ្ជកម្មថ្នាំជក់ឆ្លងរដ្ឋ ការផ្សព្វផ្សាយលក់និងការឧបត្ថម្ភកម្មវិធី និងចលនាអន្តរជាតិនៃការរត់ពន្ធ និងការផលិតបារីក្លែងក្លាយ ក៏បានជួយជ្រោមជ្រែងដល់ការកើនឡើងយ៉ាងខ្លាំងនៃការប្រើថ្នាំជក់ ។

យោងតាមវាក្យខ័ណ្ឌទី១នៃអារម្ភកថា ដែលចែងថា "ភាគីនៃអនុសញ្ញាប្តេជ្ញាថានឹងផ្តល់អាទិភាពនៃសិទ្ធិរបស់ខ្លួន ដើម្បីការពារសុខភាពសាធារណជន" អនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ គឺជាអ្នកលើកឡើងនូវការនិយមជាសាកល ។

បញ្ញត្តិសំខាន់ៗក្នុងការទាមទារឱ្យបន្ថយការប្រើប្រាស់ថ្នាំជក់នៅក្នុងអនុសញ្ញាមាននៅក្នុងមាត្រា ៦ ដល់ មាត្រា ១៤ :

- តម្លៃ និងវិធានការស្តីពីពន្ធដារ ដើម្បីបន្ថយតម្រូវការថ្នាំជក់ និង
- វិធានការមិនទាក់ទងនឹងតម្លៃ ដើម្បីបន្ថយតម្រូវការថ្នាំជក់គឺ :
    - ការការពារប្រឆាំងនឹងការរងពីផ្សែងថ្នាំជក់
    - ការដាក់បទបញ្ជាចំពោះវត្ថុដែលមាននៅក្នុងផលិតផលថ្នាំជក់
    - ការដាក់បទបញ្ជាចំពោះការបង្ហាញអោយដឹងអំពីផលិតផលថ្នាំជក់
    - ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់
    - ការអប់រំ គមនាគមន៍ ការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជន
    - ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ និង
    - វិធានការបន្ថយតម្រូវការចំពោះការញៀនថ្នាំជក់ និងការឈប់ជក់

បញ្ញត្តិសំខាន់ៗ ទាក់ទងដល់ការបន្ថយការផ្គត់ផ្គង់នៅក្នុងអនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់មាននៅក្នុងមាត្រា ១៥ ដល់មាត្រា ១៧ :

- ការធ្វើជំនួញខុសច្បាប់លើផលិតផលថ្នាំជក់
- ការលក់ទៅអោយ ឬដោយអនីតិជន និង
- ការផ្តល់ការឧបត្ថម្ភដល់សកម្មភាពជំនួសដែលអាចធ្វើអោយរស់បាន ។

លក្ខណៈពិសេសថ្មី១ផ្សេងទៀតរបស់អនុសញ្ញាគឺ ការបញ្ចូលនូវបញ្ញត្តិមួយ ដែលនិយាយអំពីការទទួលខុសត្រូវ ។ យន្តការសំរាប់ការសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស ហើយនិងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ត្រូវបានចែងនៅក្នុងមាត្រា ២០ ដល់ ២២ ។

អនុសញ្ញានៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់នឹងចូលជាធរមាន ៩០ ថ្ងៃ ក្រោយពីអនុសញ្ញានេះ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋភាគីចំនួន ៤០ ។ នៅពេលនោះ រដ្ឋភាគីដែលបានផ្តល់សច្ចាប័នត្រូវជាប់កាតព្វកិច្ចជាមួយនឹងបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។ អនុសញ្ញានៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ត្រូវបានបើកអោយចុះហត្ថលេខាពីថ្ងៃទី ១៦ ខែមិថុនា ដល់ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៣ នៅទីក្រុងហ្សឺណែវ ហើយបន្ទាប់មកនៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ដែលជាអ្នកទទួលបញ្ញើនៃសន្ធិសញ្ញា ចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ ។ រដ្ឋភាគីដែលចុះហត្ថលេខាលើអនុសញ្ញាបង្ហាញថា ខ្លួននឹងខិតខំដោយពេញទំហឹង និងដោយស្មោះត្រង់ ដើម្បីផ្តល់សច្ចាប័ន ហើយនិងបង្ហាញនូវការប្តេជ្ញាចិត្តខាងផ្លូវនយោបាយថា នឹងមិនធ្វើអោយអន្តរាយដល់គោលដៅ ដែលបានកំណត់នៅក្នុងអនុសញ្ញានេះឡើយ ។ ប្រទេសណាដែលមានបំណងចង់ក្លាយជាភាគីនៃអនុសញ្ញា បន្ទាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ អាចនឹងធ្វើបានដោយធ្វើការសុខចិត្តចូលជាសមាជិក ដែលជាដំណើរការតែមួយដំណាក់កាល ហើយនិងមានតម្លៃស្មើនឹងការផ្តល់សច្ចាប័ន ។

បណ្តាញជាសកលដែលត្រូវបានអភិវឌ្ឍន៍នៅក្នុងអំឡុងនៃរយៈពេលការចរចាសំរាប់អនុសញ្ញា មានសារសំខាន់ក្នុងការរៀបចំ ដើម្បីអនុវត្តអនុសញ្ញានៅកំរិតប្រទេស ។ នៅក្នុងសំដីរបស់លោកវេជ្ជបណ្ឌិត Jong Wook LEE ដែលជាអគ្គនាយករបស់អង្គការសុខភាពពិភពលោក :

" ការចរចានៃអនុសញ្ញានៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ បានបង្ហាញរួចទៅហើយនូវដំណើរការមួយដែលមានលទ្ធផលខុសពីមុន ជាក់ស្តែងនៅកំរិតប្រទេស ។ ជោគជ័យនៃអនុសញ្ញានៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្នុងនាមជាឧបករណ៍សំរាប់សុខភាពរបស់សាធារណជនពឹងទៅលើថាមពល និងការប្តេជ្ញាចិត្តខាងផ្លូវនយោបាយ ដែលយើងសុខចិត្តបូជា ដើម្បីអនុវត្តអនុសញ្ញានេះនៅកំរិតប្រទេស នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ។ លទ្ធផលជាជោគជ័យ គឺជ័យជំនះនៃសុខភាពសាធារណៈជាសកលសំរាប់ទាំងអស់គ្នា " ។

ដើម្បីអោយកិច្ចការនេះចេញជារូបរាងឡើង អាកប្បកិរិយា និងការប្តេជ្ញាចិត្ត ដែលបានបង្ហាញយ៉ាងប្រត្យក្ស នៅពេលធ្វើការចរចាទាមទារអោយមានការសាយភាយទៅដល់ថ្នាក់ជាតិ និងមូលដ្ឋាន នោះអនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ នឹងក្លាយទៅជាភាពពិតជាក់ស្តែងនៅទីកន្លែងដែលយើងយកចិត្តទុកដាក់បំផុតនោះ គឺនៅក្នុងប្រទេសទាំងឡាយនោះឯង ។

**អារម្ភកថា**

ភាគីនៃអនុសញ្ញានេះ

បានប្តេជ្ញាផ្តល់អាទិភាពទៅសិទ្ធិរបស់ខ្លួន ដើម្បីការពារសុខភាពសាធារណជន

ដោយទទួលស្គាល់ថា ការរាតត្បាតជម្ងឺថ្នាំជក់ គឺជាបញ្ហាសកលដែលមានផលវិបាកធ្ងន់ធ្ងរដល់សុខភាពសាធារណជន ដែលត្រូវអំពាវនាវដល់សហប្រតិបត្តិការអន្តរជាតិទូលំទូលាយបំផុត ដែលអាចធ្វើទៅបាន ហើយនិងការចូលរួមនៃប្រទេសទាំងអស់ នៅក្នុងការឆ្លើយតបជាអន្តរជាតិ ដែលមានប្រសិទ្ធភាពសមស្រប និងពេញលេញ។

ដោយឆ្លុះបញ្ចាំង និងកង្វល់របស់សហគមន៍អន្តរជាតិចំពោះការបំផ្លិចបំផ្លាញជាសកលនូវសុខភាព សង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថាន ដោយផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់។

ដោយមានកង្វល់យ៉ាងធ្ងន់ចំពោះការកើនឡើងនូវការជក់ និងការផលិតបារី និងផលិតផលថ្នាំជក់ដទៃទៀត ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាចំពោះការដាក់បន្ទុកដល់គ្រួសារ ដល់អ្នកក្រីក្រ និងដល់ប្រព័ន្ធសុខភាពជាតិ។

ដោយទទួលស្គាល់ថា ភស្តុតាងវិទ្យាសាស្ត្រត្រូវបានស្ថាបនាឡើង ដោយគ្មានការស្រពេចស្រពិល ថាការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ជាបុព្វហេតុនៃការស្លាប់ មានជម្ងឺ និងពិការ ហើយថា មានរយៈពេលបន្ទាយរវាងការរងផ្សែងថ្នាំជក់ និងការប្រើប្រាស់ផ្សេងទៀតនៃផលិតផលថ្នាំជក់ និងអាការៈដំបូងនៃជម្ងឺបណ្តាលទាក់ទងនិងថ្នាំជក់។

ដោយទទួលស្គាល់ដែរថា បារីនិងផលិតផលមួយចំនួនផ្សេងទៀតដែលមានថ្នាំជក់ ត្រូវបានផលិតតាមបែបវិទ្យាសាស្ត្រខ្ពស់ដើម្បីនឹងបង្កើត ហើយរក្សានូវការញៀន ហើយថា អង្គធាតុជាច្រើនដែលវាមាន និងផ្សែងដែលវាផលិតមានភាព សកម្មជាតិពុលមានសារធាតុដែលអាចបង្កអោយមានការផ្លាស់ប្តូរ និងមានសារធាតុអាចបង្កនូវជម្ងឺមហារីក ហើយថា ការ ញៀនបារីនេះ ត្រូវបានចាត់ទុកដោយឡែកជាចលាចលមួយនៅក្នុងចំណាត់ថ្នាក់អន្តរជាតិធំៗនៃជម្ងឺ។

ដោយទទួលស្គាល់ថា មានភស្តុតាងវិទ្យាសាស្ត្រច្បាស់លាស់ថា ការរងផ្សែងថ្នាំជក់ បណ្តាលមានភាពប៉ះពាល់មិនល្អដល់សុខភាព និងស្ថានភាពនៃការអភិវឌ្ឍន៍របស់កូនក្មេង។

ដោយមានកង្វល់ដ៏ជ្រាលជ្រៅចំពោះការកើនឡើងនូវការជក់ និងរូបភាពផ្សេងៗទៀតនៃការប្រើប្រាស់ថ្នាំជក់ ដោយកូនក្មេង និងយុវជនទូទាំងសកលលោក ជាពិសេសជក់ថ្នាំអាយុកាន់តែតិចឡើងៗ។

ដោយមានការភ្ញាក់ផ្អើលដោយសារការកើនឡើងនៃការជក់ថ្នាំ និងរូបភាពផ្សេងៗទៀតនៃការប្រើប្រាស់ថ្នាំជក់ ដោយស្ត្រី និងយុវនារីទូទាំងពិភពលោក ហើយនិងរក្សាទុកក្នុងចិត្តថា មានតម្រូវការចំពោះការចូលរួមយ៉ាងពេញទំហឹងរបស់ស្ត្រី នៅគ្រប់កំរិតនៃការសំរេចចិត្តខាងផ្នែកនយោបាយ និងការអនុវត្ត ហើយនិងតម្រូវការសំរាប់យុទ្ធសាស្ត្រនានានៃការត្រួតពិនិត្យថ្នាំជក់ដែលពាក់ព័ន្ធ ជាពិសេសដល់យែនឌ័រ។

ដោយមានកង្វល់យ៉ាងខ្លាំងចំពោះកំរិតខ្ពស់នៃការជក់ថ្នាំ និងរូបភាពផ្សេងៗទៀតនៃការប្រើប្រាស់ថ្នាំជក់ របស់ជនជាតិដើមភាគតិច។

ដោយមានកង្វល់យ៉ាងខ្លាំងចំពោះផលប៉ះពាល់នៃរូបភាពទាំងអស់នៃការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ទំនិញ និងការឧបត្ថម្ភកម្មវិធី ដែលមានគោលបំណង និងលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលថ្នាំជក់។

ដោយទទួលស្គាល់ថា សកម្មភាពជាការសហប្រតិបត្តិការមានផលប្រយោជន៍ដល់ការបំបាត់នូវការធ្វើជំនួញបារី និងផលិតផលថ្នាំជក់ដទៃទៀតដោយខុសច្បាប់ទាំងអស់ រាប់បញ្ចូលទាំងការរត់ពន្ធ ការផលិតខុសច្បាប់ និងការក្លែងបន្លំ។

ដោយទទួលស្គាល់ថា ការត្រួតពិនិត្យថ្នាំជក់នៅគ្រប់កំរិត និងជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងក្នុងប្រទេសមានសេដ្ឋកិច្ចនៅក្នុងអន្តរភាព ទាមទារនូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេសគ្រប់គ្រាន់ស្របទៅ នឹងតម្រូវការបច្ចុប្បន្ន និងគ្រោងទុកសំរាប់សកម្មភាពត្រួតពិនិត្យថ្នាំជក់។

ដោយទទួលស្គាល់នូវតម្រូវការសំរាប់អភិវឌ្ឍន៍យន្តការសមស្រប ដើម្បីដោះស្រាយការជំពាក់ទាក់ទងរយៈពេលវែងទៅនឹងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ចំពោះជោគជ័យនៃយុទ្ធសាស្ត្របន្ថយតម្រូវការថ្នាំជក់។

ដោយមានការយកចិត្តទុកដាក់ចំពោះការលំបាកផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ដែលកម្មវិធីត្រួតពិនិត្យថ្នាំជក់អាចនឹងធ្វើអោយកើតមានឡើងក្នុងរយៈពេលមធ្យម ឬរយៈពេលវែង នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចក្នុងអន្តរភាពខ្លះ ហើយទទួលស្គាល់នូវតម្រូវការរបស់ប្រទេសទាំងនោះនូវជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងបរិបទនៃយុទ្ធសាស្ត្រជាតិនានា សំរាប់ការអភិវឌ្ឍន៍មានចីរភាព។

ដោយមានមនសិការចំពោះការងារដ៏មានតម្លៃ ដែលបានធ្វើដោយប្រទេសជាច្រើន ស្តីពីការត្រួតពិនិត្យថ្នាំជក់ ហើយនិងការសរសើរដល់អគ្គមគ្គុទ្ទេសក៍របស់អង្គការសុខភាពពិភពលោក ក៏ដូចជាការខំប្រឹងប្រែងរបស់អង្គការដទៃទៀត និងអង្គភាពនានានៃប្រព័ន្ធអង្គការសហប្រជាជាតិ ហើយនិងអង្គការអន្តររដ្ឋាភិបាល អង្គការអន្តរជាតិ និងតំបន់ ក្នុងការអភិវឌ្ឍន៍យន្តការដើម្បីត្រួតពិនិត្យថ្នាំជក់។

ដោយសង្កត់ធ្ងន់ទៅលើវិភាគទានជាពិសេសរបស់អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកផ្សេងទៀត នៃសង្គមស៊ីវិល ដែលពុំមានការពាក់ព័ន្ធជាមួយនឹងឧស្សាហកម្មថ្នាំជក់ រួមមាន អង្គភាពវិជ្ជាជីវៈសុខភាព ស្ត្រី យុវជន បរិស្ថាន និងក្រុមអ្នកប្រើប្រាស់ ហើយនិងស្ថាប័នបណ្ឌិតសភា និងថែទាំសុខភាព ចំពោះការខិតខំនៅថ្នាក់ជាតិ និងអន្តរជាតិចំពោះការត្រួតពិនិត្យថ្នាំជក់ ហើយនិងសារសំខាន់ជាអាយុជីវិតចំពោះការចូលរួមនៃអង្គភាពទាំងនោះ ក្នុងការខិតខំដើម្បីត្រួតពិនិត្យថ្នាំជក់នៅថ្នាក់ជាតិ និងអន្តរជាតិ ។

ដោយទទួលស្គាល់នូវតម្រូវការនៃការប្រុងប្រយ័ត្នចំពោះការខិតខំរបស់ឧស្សាហកម្មថ្នាំជក់ ដើម្បីបំផ្លិចបំផ្លាញ និងវិទ្ធង្សនាចំពោះការខិតខំត្រួតពិនិត្យថ្នាំជក់ ហើយនិងតម្រូវការចំពោះការទទួលព័ត៌មានអំពីសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ការខិតខំត្រួតពិនិត្យថ្នាំជក់។

ដោយយោងទៅលើមាត្រា ១២ នៃកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដែលចែងថា វាជាសិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបាននូវស្តង់ដារខ្ពស់បំផុតសំរាប់សុខភាពរាងកាយ និងប្រាជ្ញា។

ដោយយោងទៅលើអាវម្ភកថានៃធម្មនុញ្ញរបស់អង្គការសុខភាពពិភពលោក ដែលចែងថា ការទទួលបាននូវសុខភាពមានស្តង់ដារខ្ពស់បំផុត ជាសិទ្ធិមូលដ្ឋានមួយសំរាប់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងរវាងជាតិសាសន៍ សាសនា ជំនឿ នយោបាយ ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ។

ដោយប្តេជ្ញាថា នឹងជំរុញវិធានការត្រួតពិនិត្យថ្នាំជក់ ដោយផ្អែកលើការពិចារណាបច្ចុប្បន្នពាក់ព័ន្ធដល់វិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ច ។

ដោយយោងទៅលើអនុសញ្ញាស្តីពីការបំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងនឹងស្ត្រី ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ ដែលចែងថា រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវតែចាត់វិធានការសមស្រប ដើម្បីបំបាត់នូវការរើសអើងប្រឆាំងនឹងស្ត្រី នៅក្នុងវិស័យថែទាំសុខភាព ។

ដោយយោងទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដែលចែងថា រដ្ឋភាគីនៃអនុសញ្ញាទទួលស្គាល់សិទ្ធិកុមារ ក្នុងការទទួលបានសុខភាពមាននូវស្តង់ដារខ្ពស់បំផុត ។

បានព្រមព្រៀងគ្នាដូចតទៅនេះ :

## ផ្នែកទី ១

## សេចក្តីផ្តើម

### មាត្រា ១

### ការប្រើពាក្យ

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

(ក) " ការធ្វើជំនួញខុសច្បាប់ " មានន័យថា ការប្រព្រឹត្ត ឬទង្វើ ដែលច្បាប់ហាមឃាត់ ហើយដែលពាក់ព័ន្ធដល់ការផលិត ការផ្ញើ ការទទួល ការកាន់កាប់ ការចែកចាយ ការលក់ ឬការទិញ រាប់បញ្ចូលទាំងការ ប្រព្រឹត្ត ឬទង្វើ ដែលមានបំណងចង់សំរួលដល់សកម្មភាពទាំងនោះ ។

(ខ) " អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" មានន័យថា ជាអង្គការមួយដែលមានរដ្ឋអធិបតេយ្យមួយចំនួនជាសមាជិក ហើយរដ្ឋជាសមាជិកទាំងនោះ បានផ្ទេរនូវសមត្ថកិច្ចលើកិច្ចការមួយចំនួន រួមបញ្ចូលទាំងអំណាចក្នុងការសំរេចសេចក្តី ដែលជាកាតព្វកិច្ចរបស់រដ្ឋជាសមាជិកទាំងនោះ ទៅអោយអង្គការនោះ ។

(គ) " ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយលក់ថ្នាំជក់" មានន័យថា គមនាគមន៍ពាណិជ្ជកម្មគ្រប់រូបភាពអនុសាសន៍ ឬសកម្មភាពដែលមានគោលបំណងអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយលក់ ផលិតផលថ្នាំជក់មួយ ឬការប្រើថ្នាំជក់ដោយផ្ទាល់ ឬដោយប្រយោល ។

(ឃ) " ការត្រួតពិនិត្យថ្នាំជក់ " មានន័យថា ជាការផ្តល់ ការទាមទារ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បីកាត់បន្ថយការបំផ្លិចបំផ្លាញ ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខភាពរបស់ប្រជាពលរដ្ឋ ដោយបំបាត់ ឬបន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ និងការរងផ្សែងថ្នាំជក់របស់ប្រជាពលរដ្ឋ។

(ង) " ឧស្សាហកម្មថ្នាំជក់ " មានន័យថា ផលិតករថ្នាំជក់ អ្នកលក់បោះដុំ និងអ្នកនាំចូលផលិតផលថ្នាំជក់ ។

(ច) " ផលិតផលថ្នាំជក់ " មានន័យថា ជាផលិតផលទាំងមូល ឬមួយចំណែក ធ្វើដោយស្លឹកថ្នាំជក់ ជាវត្ថុធាតុដើម ដែលផលិតសំរាប់យកទៅជក់ ជញ្ជក់ ទំពារ ឬហិត។

(ឆ) " ការឧបត្ថម្ភកម្មវិធីថ្នាំជក់ " មានន័យថា ជារូបភាពនៃវិភាគទានណាមួយចំពោះព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គលណាមួយ ដោយមានគោលបំណង មានអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយលក់ ផលិតផលថ្នាំជក់ ឬការប្រើប្រាស់ថ្នាំជក់ដោយផ្ទាល់ ឬដោយប្រយោល។

### មាត្រា ២

### ទំនាក់ទំនងរវាងអនុសញ្ញានេះ និងកិច្ចព្រមព្រៀង និងលិខិតតូបករណ៍គតិយុត្តផ្សេងទៀត

១- ដើម្បីនឹងការពារសុខភាពរបស់មនុស្សឱ្យបានប្រសើរជាងនេះ ភាគីត្រូវបានលើកទឹកចិត្តឱ្យអនុវត្តវិធានការលើសពីអ្វីដែលតម្រូវដោយអនុសញ្ញានេះ និងពិធីសាររបស់វា ហើយពុំមានអ្វីនៅក្នុងលិខិតតូបករណ៍នេះ ដែលបង្ការមិនអោយភាគី បង្ខំឱ្យមានតម្រូវការតឹងរ៉ឹងជាងនេះដែលមានសង្គតភាពជាមួយនឹងបទប្បញ្ញត្តិខាងលើ និងស្របតាមច្បាប់អន្តរជាតិ។

២- បទប្បញ្ញត្តិនានានៃអនុសញ្ញា និងពិធីសាររបស់វា មិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ភាគីក្នុងការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី រួមបញ្ចូលទាំងកិច្ចព្រមព្រៀងតំបន់ ឬអនុតំបន់ ស្តីពីបញ្ហាពាក់ព័ន្ធ ឬបន្ថែមលើអនុសញ្ញា និងពិធីសាររបស់វា អោយតែកិច្ចព្រមព្រៀងទាំងនោះ ស្របនឹងកាតព្វកិច្ចរបស់ភាគីនោះ ក្រោមអនុសញ្ញា និងពិធីសាររបស់វា។ ភាគីពាក់ព័ន្ធ ត្រូវប្រាប់ឱ្យដឹងអំពីកិច្ចព្រមព្រៀងទាំងនោះដល់សន្និសីទភាគី តាមរយៈអគ្គលេខាធិការដ្ឋាន។

## ផ្នែកទី ២

## គោលដៅ គោលការណ៍ណែនាំ និងកាតព្វកិច្ចទូទៅ

### មាត្រា ៣

### គោលដៅ

គោលដៅនៃអនុសញ្ញា និងពិធីសាររបស់វាគឺ ការពារជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយប្រឆាំងនឹងការបំផ្លិចបំផ្លាញសុខភាព សង្គមកិច្ច បរិស្ថាន និងសេដ្ឋកិច្ច របស់ផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ដោយផ្តល់នូវក្របខ័ណ្ឌនៃយន្តការត្រួតពិនិត្យថ្នាំជក់ ដែលត្រូវអនុវត្តដោយភាគីនៅកំរិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីបន្ថយជាបន្តបន្ទាប់ និងយ៉ាងជាក់ស្តែងនូវភាពលើសលប់នៃការប្រើថ្នាំជក់ និងការរងផ្សែងថ្នាំជក់។

## មាត្រា ៤

## គោលការណ៍ណែនាំ

ដើម្បីសំរេចបាននូវគោលដៅនៃអនុសញ្ញា និងពិធីសាររបស់វានេះ ហើយនិងអនុវត្តនូវបញ្ញត្តិរបស់វា ភាគីត្រូវទទួលការណែនាំជាអាទិ៍នូវគោលការណ៍ដូចមានចែងខាងក្រោមនេះ ÷

១- ជនគ្រប់រូបត្រូវទទួលបាននូវព័ត៌មានអំពីផលវិបាកដល់សុខភាព សភាពនៃការញៀន ហើយនិងការគំរាមកំហែងដល់ជីវិតបណ្តាលមកពីការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ហើយច្បាប់និងលិខិតបទដ្ឋានដែលមានជាប្រសិទ្ធភាព ឬវិធានការផ្សេងទៀត ដែលត្រូវបានតាក់តែងដោយភ្នាក់ងាររដ្ឋាភិបាលមានសមត្ថកិច្ច ដើម្បីការពារជនគ្រប់រូបប្រឆាំងនឹងការរងផ្សែងថ្នាំជក់ ។

២- ការប្តេជ្ញាចិត្តដ៏មោះមុតខាងផ្នែកនយោបាយជាការចាំបាច់ ដើម្បីអភិវឌ្ឍន៍ និងគាំទ្រនៅកំរិតជាតិ តំបន់ និងអន្តរជាតិនូវវិធានការពហុវិស័យដ៏ទូលំទូលាយ និងការឆ្លើយតបដែលមានសម្របសម្រួលល្អ ដែលយកចិត្តទុកដាក់ចំពោះ ÷

(ក) ការចាំបាច់ក្នុងការចាត់វិធានការ ដើម្បីការពារជនគ្រប់រូប ប្រឆាំងនឹងការរងផ្សែងថ្នាំជក់

(ខ) ការចាំបាច់ក្នុងការចាត់វិធានការ ដើម្បីបង្ការការនាំអាទិ៍ ដើម្បីជំរុញ និងគាំទ្រការឈប់ជក់ ហើយនិងដើម្បីបញ្ចុះការប្រើប្រាស់ផលិតផលថ្នាំជក់គ្រប់រូបភាព

(គ) ការចាំបាច់ក្នុងការចាត់វិធានការជំរុញអោយមានការចូលរួមរបស់ជន និងសហគមន៍ជនជាតិដើមភាគតិច ក្នុងការអភិវឌ្ឍន៍ ការអនុវត្តន៍ និងការវាយតម្លៃលើកម្មវិធីត្រួតពិនិត្យថ្នាំជក់ ដែលសមស្របទៅនឹងតម្រូវការ និងទស្សនៈផ្នែកសង្គម និងវប្បធម៌របស់គេ

(ឃ) ភាពចាំបាច់ក្នុងការចាត់វិធានការទាក់ទងដល់ហានិភ័យ ពិសេសផ្នែកយែនឌ័រ នៅពេលធ្វើការ អភិវឌ្ឍន៍យុទ្ធសាស្ត្រដើម្បីត្រួតពិនិត្យថ្នាំជក់ ។

៣- សហប្រតិបត្តិអន្តរជាតិជាពិសេសការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង និងជំនួយហិរញ្ញវត្ថុ និងការផ្តល់នូវឯកទេសពាក់ព័ន្ធ ដើម្បីបង្កើត និងអនុវត្តកម្មវិធីត្រួតពិនិត្យថ្នាំជក់ឱ្យមានប្រសិទ្ធភាព ដោយយកចិត្តទុកដាក់ដល់វប្បធម៌មូលដ្ឋានក៏ដូចជាសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងកត្តាច្បាប់ ជាផ្នែកមួយដ៏សំខាន់នៃអនុសញ្ញា ។

៤- វិធានការពហុវិស័យទូលំទូលាយ និងការឆ្លើយតបដើម្បីបន្ថយ ក៏ដូចជាដើម្បីបង្ការ ការប្រើប្រាស់នូវផលិតផលថ្នាំជក់ គ្រប់យ៉ាងនៅកំរិតជាតិ តំបន់ និងអន្តរជាតិមានសារសំខាន់ណាស់ ស្របតាមគោលការណ៍នៃសុខភាពសាធារណៈ ភាពពិការដោយការកើតមិនគ្រប់ខែ និងការស្លាប់បណ្តាលមកពីការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ។

៥- បញ្ហាទាក់ទងនឹងការទទួលខុសត្រូវដូចបានកំណត់ដោយភាគីនីមួយៗនៅក្នុងយុត្តាធិការរបស់ខ្លួន ជាផ្នែកមួយសំខាន់ក្នុងការត្រួតពិនិត្យដោយទូលំទូលាយនូវថ្នាំជក់ ។

៦- សារសំខាន់របស់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីដល់អន្តរភាពនៃសេដ្ឋកិច្ចរបស់អ្នកដាំថ្នាំជក់ និងពលករដែលជីវភាពរបស់គេត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកពីផលវិបាកនៃកម្មវិធីត្រួតពិនិត្យថ្នាំជក់ នៅក្នុងប្រទេសកំពុង

អភិវឌ្ឍន៍ជាភាគី ក៏ដូចជាភាគីដែលមានសេដ្ឋកិច្ចនៅក្នុងអន្តរភាព ត្រូវតែបានទទួលស្គាល់ និងយកចិត្តទុកដាក់នៅក្នុងបរិបទនៃយុទ្ធសាស្ត្រនានា ដែលអភិវឌ្ឍន៍នៅកំរិតជាតិសំរាប់ការអភិវឌ្ឍន៍ដោយចីរភាព។

៧- ការចូលរួមនៃសង្គមស៊ីវិលមានសារសំខាន់ណាស់ចំពោះការសំរេចបាននូវគោលដៅនៃអនុសញ្ញា និងពិធីសាររបស់វា។

## មាត្រា ៥

## កាតព្វកិច្ចទូទៅ

១- ភាគីនីមួយៗត្រូវអភិវឌ្ឍន៍ អនុវត្ត ធ្វើទំនើបកម្មតាមកាលកំណត់ និងពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ ផែនការ និងកម្មវិធី ពហុវិស័យ និងទូលំទូលាយរបស់ជាតិ ដើម្បីត្រួតពិនិត្យថ្នាំជក់ ស្របតាមអនុសញ្ញា និងពិធីសារ។

២- ដើម្បីសំរេចកិច្ចការនេះ ទៅតាមសមត្ថភាពរបស់ខ្លួន ភាគីនីមួយៗត្រូវ :

(ក) បង្កើត ឬពង្រឹង និងផ្តល់ហិរញ្ញវត្ថុដល់យន្តការសម្របសម្រួល ឬចំណុចកណ្តាលកំរិតជាតិ សំរាប់ការត្រួតពិនិត្យថ្នាំជក់ និង

(ខ) អនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានដែលមានប្រសិទ្ធភាព និង/ឬវិធានការផ្សេងទៀត និងសហប្រតិបត្តិការសមស្របជាមួយនិងភាគីផ្សេងទៀត ក្នុងការអភិវឌ្ឍន៍គោលនយោបាយសមស្របដើម្បីបង្ការ និងបន្ថយការប្រើប្រាស់ថ្នាំជក់ ការញៀនជាតិនីកូទីន និងការរងផ្សែងថ្នាំជក់។

៣- ការកំណត់ និងការអភិវឌ្ឍន៍គោលនយោបាយសុខភាពសាធារណៈទាក់ទងដល់ការត្រួតពិនិត្យថ្នាំជក់ ភាគីទាំងឡាយត្រូវធ្វើយ៉ាងណាដើម្បីការពារនូវគោលនយោបាយទាំងនោះ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម ឬផលប្រយោជន៍ផ្សេងទៀតរបស់ឧស្សាហកម្មថ្នាំជក់ ស្របតាមច្បាប់របស់ជាតិ។

៤- ភាគីទាំងឡាយត្រូវតែធ្វើសហប្រតិបត្តិការក្នុងការរៀបចំនូវវិធានការនីតិវិធី និងការណែនាំដែលបានដាក់ស្នើមកដើម្បីនឹងអនុវត្តអនុសញ្ញា និងពិធីសាររបស់វា។

៥- ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការសមស្របជាមួយនឹងអង្គការមានសមត្ថកិច្ចអន្តររដ្ឋាភិបាល អន្តរជាតិ និងតំបន់ ហើយនិងអង្គការដទៃទៀត ដើម្បីសំរេចនូវគោលដៅនៃអនុសញ្ញា និងពិធីសាររបស់វា។

៦- ទៅតាមមធ្យោបាយ និងធនធានដែលខ្លួនមាន ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការ ដើម្បីប្រមូលធនធានហិរញ្ញវត្ថុសំរាប់ការអនុវត្តអនុសញ្ញាឱ្យមានប្រសិទ្ធភាព តាមរយៈយន្តការផ្តល់ហិរញ្ញវត្ថុជាទ្វេភាគី និងពហុភាគី។

## ផ្នែកទី ៣

## វិធានការទាក់ទងនឹងការបន្ថយនូវតម្រូវការថ្នាំជក់

## មាត្រា ៦

## តម្លៃ និងវិធានការពន្ធដារ ដើម្បីបន្ថយនូវតម្រូវការថ្នាំជក់

១- ភាគីទាំងឡាយទទួលស្គាល់ថា វិធានការទាក់ទងនឹងតម្លៃ និងពន្ធដារ ជាមធ្យោបាយមួយសំខាន់ និងមានប្រសិទ្ធភាពសំរាប់បន្ថយការប្រើថ្នាំជក់ ដោយប្រភេទផ្សេងៗនៃប្រជាជន ជាពិសេសយុវជន ។

២- ដោយគ្មានការប៉ះពាល់ដល់អធិបតេយ្យភាពរបស់ភាគីទាំងឡាយ ចំពោះការកំណត់ និងបង្កើតនយោបាយពន្ធដាររបស់ខ្លួន ភាគីនីមួយៗអាចយកចិត្តទុកដាក់ចំពោះគោលដៅសុខភាពជាតិទាក់ទងនឹងការត្រួតពិនិត្យថ្នាំជក់ ហើយអនុម័ត ឬរក្សាវិធានការសមស្របដែលអាចមានជារូម ដូចតទៅ :

(ក) អនុវត្តគោលនយោបាយពន្ធដារ និងនៅកន្លែងណាសមស្រប គោលនយោបាយតម្លៃលើផលិតផលថ្នាំជក់ក៏ដូចជាវិភាគទានចំពោះគោលដៅសុខភាព ផ្តោតទៅលើការបន្ថយការប្រើថ្នាំជក់ ហើយនិង

(ខ) ហាមឃាត់ ឬដាក់កំរិតសមស្របទៅលើការលក់ទៅឱ្យ និង/ឬការនាំចូលដោយទេសចរណ៍ អន្តរជាតិនូវផលិតផលថ្នាំជក់ ដែលឥតយកពន្ធអាករ ។

៣- ភាគីទាំងឡាយត្រូវផ្តល់អត្រាពន្ធសំរាប់ផលិតផលថ្នាំជក់ ហើយនិងការនិយមក្នុងការប្រើថ្នាំជក់ នៅក្នុងរបាយការណ៍តាមពេលកំណត់ទៅសន្និសីទភាគី ស្របតាមមាត្រា ២១ ។

## មាត្រា ៧

## វិធានការមិនទាក់ទងនឹងតម្លៃ ដើម្បីបន្ថយនូវតម្រូវការថ្នាំជក់

ភាគីទាំងឡាយទទួលស្គាល់ថា វិធានការដ៏ទូលំទូលាយដែលមិនទាក់ទងនឹងតម្លៃជាមធ្យោបាយមួយដ៏សំខាន់ និងមានប្រសិទ្ធភាពសំរាប់បន្ថយការប្រើថ្នាំជក់ ។ ភាគីនីមួយៗ ត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការចាំបាច់ដទៃទៀត ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របតាមមាត្រា ៨ ដល់ ១៣ ហើយត្រូវធ្វើសហប្រតិបត្តិការជាមួយនឹងភាគីដទៃទៀត ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីអនុវត្តនូវវិធានការទាំងនោះ ។ សន្និសីទភាគីត្រូវស្នើសេចក្តីណែនាំសមរម្យសំរាប់ការអនុវត្តបញ្ញត្តិនៃមាត្រាទាំងនោះ ។

## មាត្រា ៨

## ការការពារនឹងការរងផ្សែងថ្នាំជក់

១- ភាគីទាំងឡាយទទួលស្គាល់ថា ភស្តុតាងវិទ្យាសាស្ត្របានបង្ហាញដោយគ្មានការស្រពេចស្រពិលថា ការរងផ្សែងថ្នាំជក់ ជាបុព្វហេតុនៃការស្លាប់ ការមានជម្ងឺ និងពិការភាព ។

២- ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តនៅក្នុងវិស័យនៃយុត្តាធិការជាតិមានស្រាប់ ដូចមានកំណត់ដោយច្បាប់ជាតិ ហើយជំរុញយ៉ាងសកម្មនៅក្នុងយុត្តាធិការដទៃទៀត ការអនុម័ត និងការអនុវត្តនូវច្បាប់ និងលិខិតបទដ្ឋាន មានប្រសិទ្ធភាព

ហើយ/ឬវិធានការដទៃទៀត ដែលផ្តល់ការការពារប្រឆាំងនឹងការរងផ្សែងថ្នាំជក់នៅក្នុងកន្លែងធ្វើការ តាមមធ្យោបាយដឹកជញ្ជូនសាធារណៈ នៅក្នុងអាគារសំរាប់សាធារណជន ហើយនិងកន្លែងសំរាប់សាធារណជនដទៃទៀត ។

## មាត្រា ៩

## បទបញ្ញាចំពោះវត្ថុធាតុដែលមាននៅក្នុងផលិតផលថ្នាំជក់

សន្និសីទភាគី ដោយមានការពិគ្រោះយោបល់ជាមួយអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវស្នើសេចក្តីណែនាំ ដើម្បីធ្វើតេស្ត និងវាស់សមាសធាតុ និងការបញ្ចេញ(ផ្សែង)របស់ផលិតផលថ្នាំជក់ និងដើម្បីបទបញ្ញាសំរាប់សមាសធាតុ និងការបញ្ចេញ(ផ្សែង)នោះ។ នៅកន្លែងដែលមានការអនុម័តដោយអាជ្ញាធរជាតិមានសមត្ថកិច្ច ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការផ្សេងទៀត សំរាប់ធ្វើតេស្ត និងវាស់ ហើយនិងសំរាប់បទបញ្ញានោះ ។

## មាត្រា ១០

## បទបញ្ញាចំពោះការប្រាប់ឱ្យដឹងអំពីផលិតផលថ្នាំជក់

ស្របតាមច្បាប់ជាតិរបស់ខ្លួន ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការផ្សេងទៀត តម្រូវឱ្យផលិតករ និងអ្នកនាំចូលនូវផលិតផលថ្នាំជក់ បង្ហាញប្រាប់ដល់អាជ្ញាធររដ្ឋាភិបាលនូវព័ត៌មានទាក់ទងនឹងសមាសធាតុ និងការបញ្ចេញ(ផ្សែង)របស់ផលិតផលថ្នាំជក់។ ភាគីនីមួយៗត្រូវអនុម័ត អនុវត្តនូវវិធានការមានប្រសិទ្ធភាពសំរាប់ការបង្ហាញប្រាប់សាធារណជន នូវព័ត៌មានទាក់ទងនឹងសមាសធាតុពុលនៃផលិតផលថ្នាំជក់ និងការបញ្ចេញ(ផ្សែង)ដែលវាអាចផលិត។

## មាត្រា ១១

## ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់

១- ភាគីនីមួយៗនៅក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់ភាគីនោះ ត្រូវអនុម័ត និងអនុវត្តស្របតាមច្បាប់ជាតិរបស់ខ្លួន នូវវិធានការមានប្រសិទ្ធភាពដើម្បីធានាថា :

(ក) ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់ ពុំមែនផ្សព្វផ្សាយដើម្បីលក់ផលិតផលថ្នាំជក់ ដោយមធ្យោបាយដែលមិនពិត នាំអោយយល់ខុស ដែលឆបោក ឬហាក់ដូចជាបង្កើតអោយមានអារម្មណ៍ ដែលមានការភាន់ច្រឡំចំពោះលក្ខណៈរបស់វា ប៉ះពាល់ដល់សុខភាព គ្រោះថ្នាក់ ឬការបញ្ចេញ(ផ្សែង) រាប់បញ្ចូលទាំងការពិពណ៌នា សញ្ញាពាណិជ្ជកម្ម អត្ថបដិរូប ឬសញ្ញាដទៃទៀតណា ដែលបង្កើតនូវអារម្មណ៍មិនពិត ដោយផ្ទាល់ ឬដោយប្រយោលថា ផលិតផលថ្នាំជក់ពិសេសមួយ មានគ្រោះថ្នាក់តិចជាង

ផលិតផលថ្នាំជក់ដទៃទៀត។ នេះអាចរាប់បញ្ចូលនូវពាក្យដូចជា " មានជ័រតិច " " ស្រាល " " ស្រាល-បំផុត " ឬ " មិនខ្លាំង " ហើយនិង

(ខ) ដុំ ឬកញ្ចប់នីមួយៗនៃផលិតផលថ្នាំជក់ ហើយនិងប្រដាប់វេចខ្ចប់ និងផ្លាកខាងក្រៅណាមួយនៃផលិតផលនោះ ក៏ត្រូវមានបំរាមសុខភាពពិពណ៌នាអំពីគ្រោះថ្នាក់នៃការប្រើថ្នាំជក់ ឬអាចបញ្ចូលនូវសារសមរម្យដទៃទៀត។ បំរាម ឬសារទាំងនោះ :

i) ត្រូវតែបានអនុម័តដោយអាជ្ញាធរជាតិមានសមត្ថកិច្ច

ii) ត្រូវតែផ្លាស់ប្តូរ

iii) ត្រូវតែមានទំហំធំច្បាស់លាស់មើលឃើញច្បាស់ និងអាចអានបាន

iv) ត្រូវមាន ៥០% ឬច្រើនជាងនៃកន្លែងដែលត្រូវបង្ហាញសំខាន់បំផុត ប៉ុន្តែមិនត្រូវអោយតិចជាង ៣០% នៃកន្លែងដែលត្រូវបង្ហាញសំខាន់បំផុត

v) អាចជារាង ឬមានបញ្ចូលនូវរូបភាព ឬរូបភាពជាសារ

២- ដុំ ឬកញ្ចប់នីមួយៗនៃផលិតផលថ្នាំជក់ ហើយនិងប្រដាប់វេចខ្ចប់ ឬផ្លាកខាងក្រៅរបស់ផលិតផលនោះ ត្រូវបន្ថែមលើបំរាមដែលបានចែងនៅក្នុងវាក្យខ័ណ្ឌលេខ ១ (ខ) នៃមាត្រានេះ មានព័ត៌មានស្តីពីសមាសធាតុពាក់ព័ន្ធនឹងការបញ្ចេញ(ផ្សែង)របស់ផលិតផលថ្នាំជក់ដូចមានការអោយនិយមន័យ ដោយអាជ្ញាធរជាតិ។

៣- ភាគីនីមួយៗ ត្រូវទាមទារថា បំរាម ឬអត្ថបទព័ត៌មានដូចមានចែងក្នុងវាក្យខ័ណ្ឌ ១(ខ) និង វាក្យខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវតែមានលើដុំ ឬកញ្ចប់នីមួយៗនៃផលិតផលថ្នាំជក់ ហើយនិងប្រដាប់វេចខ្ចប់ ឬផ្លាកខាងក្រៅរបស់ផលិតផលនោះ ជាភាសាជាតិ ឬភាសាដទៃទៀត។

៤- សំរាប់គោលបំណងនៃមាត្រានេះ ពាក្យថា "ប្រដាប់វេចខ្ចប់ ឬផ្លាកខាងក្រៅ " ទាក់ទងនឹងផលិតផលថ្នាំជក់ គឺអនុវត្ត ទៅលើកញ្ចប់និងផ្លាកដែលប្រើសំរាប់ការលក់រាយនៃផលិតផល។

## មាត្រា ១២

## ការអប់រំ ការផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជន

១- ភាគីនីមួយៗត្រូវផ្សព្វផ្សាយ និងពង្រឹងការយល់ដឹងរបស់សាធារណជនអំពីបញ្ហាត្រួតពិនិត្យថ្នាំជក់ ដោយប្រើគ្រប់មធ្យោបាយគមនាគមន៍ដែលមាន។ ដើម្បីសំរេចកិច្ចការនេះ ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការផ្សេងទៀត ដើម្បីនឹងផ្សព្វផ្សាយជំរុញ :

(ក) លទ្ធភាពទទួលបាននូវកម្មវិធីអប់រំ និងការយល់ដឹងរបស់សាធារណជនយ៉ាងទូលំទូលាយ មានប្រសិទ្ធភាពអំពីហានិភ័យសុខភាព រួមបញ្ចូលទាំងលក្ខណៈញៀននៃការប្រើថ្នាំជក់ និងការរងផ្សែងថ្នាំជក់

ខ- ការយល់ដឹងរបស់សាធារណជនអំពីហានិភ័យសុខភាពនៃការប្រើថ្នាំជក់ និងការរងផ្សែងថ្នាំជក់ និងអំពីផលប្រយោជន៍នៃការឈប់ប្រើថ្នាំជក់ និងរបៀបរស់នៅដោយគ្មានថ្នាំជក់ ដូចមានចែងក្នុងមាត្រា ១៤.២

(គ) លទ្ធភាពទទួលបានព័ត៌មានយ៉ាងទូលំទូលាយ ស្តីពីឧស្សាហកម្មថ្នាំជក់ ដែលពាក់ព័ន្ធនឹងគោលដៅរបស់អនុសញ្ញានេះ របស់សាធារណជនស្របតាមច្បាប់ជាតិ

(ឃ) ការបណ្តុះបណ្តាលមានប្រសិទ្ធភាព និងសមស្រប ឬការបញ្ចុះបញ្ចូល និងកម្មវិធីយល់ដឹងអំពីការត្រួតពិនិត្យថ្នាំជក់ដល់ជនដូចជា អ្នកធ្វើការក្នុងវិស័យសុខាភិបាល អ្នកធ្វើការក្នុងសហគមន៍ អ្នកធ្វើការក្នុងវិស័យសង្គមកិច្ច អ្នកធ្វើការក្នុងវិស័យផ្សព្វផ្សាយព័ត៌មាន អ្នកអប់រំ និងអ្នកមានអំណាចសំរេចអភិបាល និងជនដែលពាក់ព័ន្ធដទៃទៀត

(ង) ការយល់ដឹង និងការចូលរួមរបស់ភ្នាក់ងារសាធារណៈ ឬឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលពុំមានការទាក់ទងជាមួយនឹងឧស្សាហកម្មថ្នាំជក់ ក្នុងការអភិវឌ្ឍន៍ និងអនុវត្តកម្មវិធីអន្តរវិស័យ និងយុទ្ធសាស្ត្រសំរាប់ការត្រួតពិនិត្យថ្នាំជក់ និង

(ច) ការយល់ដឹងរបស់សាធារណជន និងការទទួលបានព័ត៌មានទាក់ទងនឹងភាពមិនអនុគ្រោះដល់សុខភាព សេដ្ឋកិច្ច និងបរិស្ថាន ដែលជាផលវិបាកនៃផលិតផល និងការប្រើប្រាស់ថ្នាំជក់។

## មាត្រា ១៣

## ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់

១- ភាគីទាំងឡាយទទួលស្គាល់ថា ការហាមឃាត់ដ៏ទូលំទូលាយមួយចំពោះការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធី អាចនឹងបន្ថយការប្រើផលិតផលថ្នាំជក់ ។

២- ភាគីនីមួយៗ អនុលោមស្របតាមរដ្ឋធម្មនុញ្ញ ឬគោលការណ៍ធម្មនុញ្ញរបស់ខ្លួន ត្រូវធ្វើការហាមឃាត់ដ៏ទូលំទូលាយចំពោះរាល់ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ ។ ទាំងនេះត្រូវរាប់បញ្ចូលការហាមឃាត់ដ៏ទូលំទូលាយមួយចំពោះការផ្សាយពាណិជ្ជកម្មឆ្លងព្រំដែន ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដែលមានដើមកំណើតពីប្រទេសរបស់ខ្លួន ស្របទៅតាមបរិស្ថានគតិយុត្ត និងមធ្យោបាយបច្ចេកទេសដែលភាគីនោះមាន ។ ដូច្នេះ នៅក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីការចូលជាធរមានរបស់អនុសញ្ញានេះ ភាគីនីមួយៗត្រូវតាក់តែងច្បាប់ និងលិខិតបទដ្ឋានសមស្រប និង/ឬវិធានការផ្សេងទៀត ហើយធ្វើរបាយការណ៍ អនុលោមតាមមាត្រា ២១ ។

៣- ភាគីដែលពុំអាចធ្វើការហាមឃាត់ដ៏ទូលំទូលាយបាន ដោយសារតែរដ្ឋធម្មនុញ្ញ ឬគោលការណ៍ធម្មនុញ្ញរបស់ខ្លួន ត្រូវអនុវត្តការរឹតទៅលើរាល់ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់។ យោងទៅលើបរិស្ថានគតិយុត្ត និងមធ្យោបាយបច្ចេកទេសដែលភាគីនោះមាន ការរឹតនេះ រួមមានការរឹត ឬការហាមឃាត់ដ៏ទូលំទូលាយចំពោះការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធី ដែលមានដើមកំណើតចេញពីប្រទេសរបស់ខ្លួន ហើយមានអានុភាពឆ្លងព្រំដែន។ ដូច្នេះ ភាគីនីមួយៗត្រូវតាក់តែងច្បាប់ និងលិខិតបទដ្ឋានសមស្រប និង/ឬវិធានការដទៃទៀត ហើយធ្វើរបាយការណ៍ អនុលោមតាមមាត្រា ២១ ។

៤- យ៉ាងហោចណាស់ អោយស្របទៅតាមរដ្ឋធម្មនុញ្ញ ឬគោលការណ៍ធម្មនុញ្ញរបស់ខ្លួន ភាគីនីមួយៗត្រូវ :

(ក) ហាមឃាត់រាល់រូបភាពនៃការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ ដែលលើកតម្កើងផលិតផលថ្នាំជក់មួយ ដោយមធ្យោបាយដែលមិនពិត នាំអោយយល់ខុស ឬបោក-បញ្ឆោត ឬអាចបង្កើតអោយមានការភ័ន្តច្រឡំទៅលើលក្ខណៈ ការប៉ះពាល់ដល់សុខភាព គ្រោះថ្នាក់ ឬការបញ្ចេញ (ផ្សែង)

(ខ) ទាមទារអោយមានបំរាម ឬសារពាក់ព័ន្ធដល់សុខភាពនៅលើការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់

(គ) ដាក់កំរិតលើការប្រើរង្វាន់លើកទឹកចិត្តដោយផ្ទាល់ ឬដោយប្រយោល ដែលទាក់ទាញអោយសាធារណៈ-ជនទិញផលិតផលថ្នាំជក់

(ឃ) បើសិនជាគ្មានការហាមឃាត់ដ៏ទូលំទូលាយទេ ទាមទារការបង្ហាញប្រាប់ដល់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ អំពីចំណាយរបស់ឧស្សាហកម្មថ្នាំជក់ទៅលើការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដែលពុំទាន់ត្រូវបានហាមឃាត់។ អាជ្ញាធរទាំងនោះ អាចសំរេចផ្តល់ព័ត៌មានអំពីចំណាយនោះ ដល់សាធារណជន និងសន្និសីទភាគី ស្របតាមមាត្រា ២១ បើសិនជាច្បាប់ជាតិអនុញ្ញាតអោយ

(ង) ធ្វើការហាមឃាត់ដ៏ទូលំទូលាយមួយ ឬក្នុងករណីដែលភាគីមួយមិនអាចធ្វើការហាមឃាត់ដ៏ទូលំទូលាយ ដោយសាររដ្ឋធម្មនុញ្ញ ឬគោលការណ៍ធម្មនុញ្ញរបស់ខ្លួន ដាក់កំរិតលើការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ នៅក្នុងវិទ្យុ ទូរទស្សន៍ ការផ្សព្វផ្សាយព័ត៌មានតាមការបោះពុម្ព ហើយនិងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀត ដូចជា អ៊ិនធឺណែតនៅក្នុងរយៈពេល ៥ ឆ្នាំ

(ច) ហាមឃាត់ ឬក្នុងករណីដែលភាគីមួយពុំមានលទ្ធភាពនឹងហាមឃាត់ ឬដោយសាររដ្ឋធម្មនុញ្ញ ឬគោលការណ៍ធម្មនុញ្ញរបស់ខ្លួនដាក់កំរិត ហាមឃាត់ការឧបត្ថម្ភកម្មវិធីសំរាប់ព្រឹត្តិការណ៍អន្តរជាតិ សកម្មភាព និង/ឬអ្នកចូលរួម

៥- ភាគីទាំងឡាយត្រូវបានលើកទឹកចិត្តអោយអនុវត្តវិធានការលើសពីកាតព្វកិច្ច ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ៤ ។

៦- ភាគីទាំងឡាយ ត្រូវធ្វើសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យា និងមធ្យោបាយផ្សេងទៀតដែលចាំបាច់ក្នុងការសំរួលការបំបាត់ចោលនូវការផ្សាយពាណិជ្ជកម្មឆ្លងព្រំដែន។

៧- ភាគីទាំងឡាយដែលបានធ្វើការហាមឃាត់លើរូបភាពខ្លះនៃការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ មានអធិបតេយ្យភាពក្នុងការហាមឃាត់រូបភាពនៃការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីឆ្លងព្រំដែន ដែលចូលមកក្នុងទឹកដីរបស់ខ្លួន ហើយនិងដាក់ពិន័យស្មើគ្នានិងពិន័យដែលអនុវត្តសំរាប់ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីនៅក្នុងស្រុកដែលមានដើមកំណើតចេញមកពីទឹកដីរបស់ខ្លួន ស្របទៅតាមច្បាប់ជាតិរបស់ខ្លួន។ វាក្យខ័ណ្ឌនេះ ពុំឯកភាព ឬ យល់ព្រមចំពោះការពិន័យពិសេសណាមួយឡើយ។

៨- ភាគីទាំងឡាយត្រូវពិចារណាលើការតាក់តែងពិធីសារមួយ ដែលចែងអំពីវិធានការសមស្រប ទាមទារការសហការអន្តរជាតិ ដើម្បីការហាមឃាត់ដ៏ទូលំទូលាយមួយទៅលើការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីឆ្លងព្រំដែន។

## មាត្រា ១៤

## វិធានការបន្ថយការញៀនថ្នាំ និងការឈប់ជក់ថ្នាំ

១- ភាគីនីមួយៗត្រូវអនុវត្ត និងផ្សព្វផ្សាយសេចក្តីណែនាំរួម សមស្រប និងទូលំទូលាយមួយ ដែលផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ និងទម្លាប់ដ៏ល្អបំផុត ដោយយកចិត្តទុកដាក់ទៅលើអាទិភាព និងកាលៈទេសៈរបស់ជាតិ ហើយត្រូវចាត់វិធានការមានប្រសិទ្ធភាព ដើម្បីជំរុញការឈប់ប្រើថ្នាំជក់ និងការព្យាបាលត្រឹមត្រូវ ចំពោះការញៀនថ្នាំជក់។

២- ដើម្បីសំរេចកិច្ចការនេះ ភាគីនីមួយៗត្រូវខិតខំ :

(ក) រចនា និងអនុវត្តកម្មវិធីមានប្រសិទ្ធភាពសំដៅជំរុញការឈប់ប្រើថ្នាំជក់នៅក្នុងទីកន្លែង ដូចជា ស្ថាប័នអប់រំ កន្លែងថែទាំសុខភាព កន្លែងធ្វើការ និងកន្លែងធ្វើកីឡា

(ខ) បញ្ចូលការធ្វើរោគវិនិច្ឆ័យ និងព្យាបាលការញៀនថ្នាំជក់ និងសេវាផ្តល់ប្រឹក្សាលើការឈប់ប្រើថ្នាំជក់ នៅក្នុងកម្មវិធី ផែនការ និងយុទ្ធសាស្ត្រអប់រំជាតិចំពោះសុខភាព ជាមួយនិងការចូលរួមរបស់មន្ត្រីសុខាភិបាល មន្ត្រីសហគមន៍ និងមន្ត្រីសង្គមកិច្ច

(គ) បង្កើតកន្លែងថែទាំសុខភាព និងមជ្ឈមណ្ឌលកម្មវិធីនីតិសម្បទាសំរាប់ការធ្វើរោគវិនិច្ឆ័យ ការផ្តល់ឱវាទ ការបង្ការ និងការព្យាបាលការញៀនថ្នាំជក់

(ឃ) សហការជាមួយភាគីផ្សេងទៀត ដើម្បីសំរួលការទទួលបាននូវការព្យាបាលការញៀនថ្នាំជក់ រួមបញ្ចូលទាំងថ្នាំសង្កូវ ស្របតាមមាត្រា ២២ ផលិតផលទាំងនេះនិងសមាសធាតុរបស់វា អាចរាប់បញ្ចូលនូវថ្នាំពេទ្យ ផលិតផលដែលប្រើសំរាប់អោយថ្នាំពេទ្យ និងការធ្វើរោគវិនិច្ឆ័យនៅពេលណាសមស្រប។

## ផ្នែកទី ៤

## វិធានការទាក់ទងដល់ការបន្ថយការផ្គត់ផ្គង់ថ្នាំជក់

## មាត្រា ១៥

## ការធ្វើជំនួញខុសច្បាប់លើផលិតផលថ្នាំជក់

១- ភាគីទាំងឡាយទទួលស្គាល់ថា ការបំបាត់នូវរាល់រូបភាពធ្វើពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ រាប់បញ្ចូលទាំងការរត់ពន្ធ ការផលិតដោយខុសច្បាប់ និងការក្លែងបន្លំ និងការអភិវឌ្ឍន៍ និងការអនុវត្តច្បាប់ជាតិពាក់ព័ន្ធ បន្ថែមលើកិច្ចព្រមព្រៀងអនុតំបន់ តំបន់ និងជាសកល គឺជាសមាសធាតុដ៏សំខាន់សំរាប់ធ្វើការត្រួតពិនិត្យថ្នាំជក់។

២- ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ លិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការផ្សេងទៀត ដើម្បីធានាថា ដុំ និងកញ្ចប់នីមួយៗនៃផលិតផលថ្នាំជក់ ហើយនិងប្រដាប់វេចខ្ចប់ខាងក្រៅរបស់ផលិតផលនោះ ត្រូវបានបង្ហាញដើម្បីជួយដល់ភាគីក្នុងការកំណត់ប្រភពនៃផលិតផលថ្នាំជក់ ហើយអនុលោមតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីពាក់ព័ន្ធ ជួយដល់ភាគីទាំងឡាយក្នុងការកំណត់ចំណុចបន្វែបន្លំ ហើយតាមដានត្រួតពិនិត្យឯកសារ និងត្រួតពិនិត្យចលនានៃផលិតផលថ្នាំជក់ និងល័ក្ខខ័ណ្ឌគតិយុត្តរបស់វា។ លើសពីនេះទៅទៀត ភាគីនីមួយៗត្រូវ :

(ក) តម្រូវអោយមាន នៅលើដុំ និងកញ្ចប់នីមួយៗនៃផលិតផលថ្នាំជក់ សំរាប់ការលក់រាយ និងលក់ដុំ នៅក្នុងផ្សារនៅក្នុងប្រទេស អត្ថបទសរសេរថា " លក់បានតែក្នុង( បញ្ចូល ឈ្មោះប្រទេស ដែនដីចំណុះ តំបន់ ឬសហព័ន្ធ)" ឬមានសរសេរអត្ថបទមានប្រសិទ្ធភាពផ្សេងទៀត ដែលបង្ហាញអំពីទីកន្លែងចុងក្រោយបំផុត ឬដែលអាចជួយដល់អាជ្ញាធរក្នុងការ កំណត់ថាតើផលិតផលនោះ ជាផលិតផលស្របច្បាប់សំរាប់លក់នៅក្នុងទីផ្សារក្នុងប្រទេស

(ខ) ពិចារណាក្នុងការអភិវឌ្ឍន៍ តាមដានជាក់ស្តែង និងតាមដានរបបធានាប្រព័ន្ធចែកចាយ និងជួយក្នុងការស៊ើបអង្កេតរកការធ្វើជំនួញខុសច្បាប់ ។

៣- ភាគីនីមួយៗតម្រូវអោយមានព័ត៌មាន ឬសញ្ញាពិសេសនៅលើកញ្ចប់ដូចមានចែងនៅក្នុង វាក្យខ័ណ្ឌទី ២ នៃមាត្រានេះ នៅលើកញ្ចប់ ដែលអាចអានបាន ឬ/និងសរសេរជាភាសាជាតិ ឬ ភាសាផ្សេងទៀតនៅលើកញ្ចប់ ឬអត្ថបទពិសេស។

៤- ក្នុងគោលបំណងបំបាត់នូវការធ្វើជំនួញខុសច្បាប់នៃផលិតផលថ្នាំជក់ ភាគីនីមួយៗត្រូវ :

(ក) តាមដានត្រួតពិនិត្យ និងប្រមូលទិន្នន័យនៃការធ្វើជំនួញផលិតផលថ្នាំជក់ឆ្លងព្រំដែន រាប់បញ្ចូលទាំងការធ្វើជំនួញខុសច្បាប់ និងការប្តូរព័ត៌មានគ្នាទៅវិញទៅមករវាងអាជ្ញាធរគយ ពន្ធដារ និងអាជ្ញាធរផ្សេងទៀត ហើយនិងស្របតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីពាក់ព័ន្ធ និងជាធរមាន

(ខ) តាក់តែង ឬពង្រឹងច្បាប់ដែលមានការពិន័យសមស្របចំពោះការធ្វើជំនួញលើផលិតផលថ្នាំជក់ខុសច្បាប់ រាប់បញ្ចូលទាំងការក្លែងបន្លំ និងការរត់ពន្ធបារី

(គ) ចាត់វិធានការសមស្របតាមដំណាក់កាលដើម្បីធានាថា រាល់បរិក្ខារផលិតដែលបានរឹបអូស ការក្លែងបន្លំ និងការរត់ពន្ធបារី និងផលិតផលថ្នាំជក់ដទៃទៀត ត្រូវបានបំផ្លាញចោល ដោយប្រើវិធីសាស្ត្រ មិនផ្តល់គ្រោះថ្នាក់ដល់បរិស្ថាន បើអាចធ្វើទៅបាន ឬចាត់ចែងទៅតាមច្បាប់ជាតិ

(ឃ) អនុម័ត និងអនុវត្តវិធានការ ដើម្បីត្រួតពិនិត្យតាមដាន កសាងឯកសារ និងត្រួតពិនិត្យកន្លែងរក្សាទុក និងការចែកចាយនៃផលិតផលថ្នាំជក់ដែលចាប់បាន ឬចលនានៅក្រោមការព្យួរពន្ធ ឬពន្ធគយ នៅក្នុងយុត្តាធិការរបស់ខ្លួន

ង- អនុម័តវិធានការសមស្របដើម្បីរឹបអូសផលចំណេញបានមកពីការធ្វើជំនួញផលិតផលថ្នាំជក់ខុសច្បាប់ ។

៥- ព័ត៌មានដែលប្រមូលបានស្របតាមវាក្យខ័ណ្ឌ ៤(ក) និង ៤(ឃ) នៃមាត្រានេះ ត្រូវបានផ្តល់ជារូបភាពសង្ខេប ដោយភាគីនានា នៅក្នុងរបាយការណ៍តាមពេលកំណត់ទៅសន្និសីទភាគី យោងតាមមាត្រា ២១ ។

៦- ភាគីនានា បើអាចធ្វើទៅបាននិងអនុលោមតាមច្បាប់ជាតិ ត្រូវជំរុញការធ្វើសហប្រតិបត្តិការរវាងភ្នាក់ងារជាតិនានា ក៏ដូចជាអង្គការអន្តររដ្ឋាភិបាល អន្តរជាតិ អន្តរតំបន់ពាក់ព័ន្ធ ដែលទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ និងដំណើររឿងក្តី ក្នុងគោលបំណងបំបាត់ការធ្វើជំនួញផលិតផលថ្នាំជក់ខុសច្បាប់ ។ ត្រូវមានការសង្កត់ធ្ងន់ជាពិសេសលើសហប្រតិបត្តិការនៅថ្នាក់តំបន់ និងអនុតំបន់ក្នុងការប្រយុទ្ធប្រឆាំងនិងការធ្វើជំនួញផលិតផលថ្នាំជក់ខុសច្បាប់ ។

៧- ភាគីនីមួយៗត្រូវខិតខំខ្ទែងអនុម័ត និងអនុវត្តវិធានការផ្សេងទៀត រួមមាន ការផ្តល់អាជ្ញាប័ណ្ណ នៅពេលសមស្រប ដើម្បីត្រួតពិនិត្យ ឬធ្វើអោយត្រឹមត្រូវតាមច្បាប់នូវការផលិត និងការចែកចាយផលិតផលថ្នាំជក់ ដើម្បីបង្ការការធ្វើជំនួញខុសច្បាប់ ។

## មាត្រា ១៦

## ការលក់ទៅអោយ ឬដោយអនីតិជន

១- ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការដទៃទៀត នៅតាមភ្នាក់ងាររដ្ឋាភិបាលមានសមត្ថកិច្ច ដើម្បីហាមឃាត់ការលក់ផលិតផលថ្នាំជក់ទៅអោយអនីតិជនដែលច្បាប់មូលដ្ឋាន និងច្បាប់ជាតិកំណត់ ឬក្រោមអាយុ ១៨ ឆ្នាំ ។ វិធានការទាំងនោះ អាចមាន :

(ក) តម្រូវអោយអ្នកលក់ផលិតផលថ្នាំជក់ទាំងអស់ដាក់បង្ហាញយ៉ាងច្បាស់ និងលេចធ្លោនូវកន្លែងលក់របស់ខ្លួននៅអត្ថបទស្តីពីការហាមឃាត់ ការលក់ថ្នាំជក់ទៅអោយអនីតិជន ហើយក្នុងករណីមានការសង្ស័យត្រូវទាមទារដល់អ្នកទិញថ្នាំជក់នីមួយៗអោយផ្តល់នូវភស្តុតាងសមស្របថា ខ្លួនមានអាយុស្របច្បាប់ហើយ

(ខ) ហាមឃាត់ការលក់ផលិតផលថ្នាំជក់តាមរបៀបដែលធ្វើអោយអ្នកទិញអាចយករបស់ដែលដាក់លក់ដោយខ្លួនឯងបាន ដូចជា ធ្នើរនៅក្នុងហាងលក់អីវ៉ាន់

(គ) ហាមឃាត់មិនអោយលក់ស្ករគ្រាប់ នំចំណី ប្រដាប់ក្មេងលេង ឬរបស់អ្វីផ្សេងទៀត ដែលមានរាងជាផលិតផលថ្នាំជក់ ដើម្បីទាក់ទាញអនីតិជន

(ឃ) ធានាថា ម៉ាស៊ីនលក់ថ្នាំជក់នៅក្រោមយុត្តាធិការរបស់ខ្លួន មិនអាចអោយអនីតិជនយកខ្លួនឯងបានទេ ហើយមិនជំរុញអោយអនីតិជនលក់ផលិតផលថ្នាំជក់ទេ ។

២- ភាគីនីមួយៗត្រូវហាមឃាត់ ឬជំរុញអោយមានការហាមឃាត់នូវការចែកចាយមិនយកប្រាក់នូវផលិតផលថ្នាំជក់ដល់សាធារណជន និងជាពិសេសដល់អនីតិជន ។

៣- ភាគីនីមួយៗត្រូវខិតខំខ្ទែង ហាមឃាត់ការលក់រាយនូវបារីមួយដើមៗ ឬជាកញ្ចប់តូច ដែលបង្កើននូវលទ្ធភាពទិញផលិតផលនោះ ដោយអនីតិជន ។

៤- ភាគីទាំងឡាយទទួលស្គាល់ថា ដើម្បីនឹងបង្កើននូវប្រសិទ្ធភាពរបស់ខ្លួន វិធានការទាំងឡាយដែលបង្ការការលក់ផលិតផលថ្នាំជក់ទៅអោយអនីតិជនត្រូវ នៅពេលសមស្រប ភ្ជាប់ជាមួយនឹងបញ្ញត្តិដទៃទៀតដែលមាននៅក្នុងអនុសញ្ញានេះ។

៥- នៅពេលចុះហត្ថលេខាផ្តល់សច្ចាប័ន យល់ព្រម អនុម័ត ឬសុខចិត្តចូលជាសមាជិកនៃអនុសញ្ញា ឬនៅពេលណាមួយបន្ទាប់មក ភាគីមួយអាច តាមសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរមួយ បង្ហាញអំពីការប្តេជាចិត្តរបស់ខ្លួន ក្នុងការអនុញ្ញាតអោយបញ្ចូលម៉ាស៊ីនលក់ថ្នាំជក់ទៅក្នុងយុត្តាធិការរបស់ខ្លួន ឬតាមដែលអាចធ្វើទៅបាន ហាមឃាត់មិនអោយមានម៉ាស៊ីនលក់ថ្នាំជក់ដាច់ខាត។ សេចក្តីប្រកាសដែលធ្វើទៅតាមមាត្រានេះ ត្រូវផ្ញើជូនភាគីទាំងអស់នៃអនុសញ្ញាដោយអ្នកទទួលបញ្ញើ។

៦- ភាគីនីមួយៗត្រូវអនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានមានប្រសិទ្ធភាព ឬវិធានការផ្សេងទៀត រួមបញ្ចូលទាំងការដាក់ពិន័យអ្នកលក់ និងអ្នកចែកចាយ ដើម្បីធានាការគោរពតាមកាតព្វកិច្ចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ ១.៥ នៃមាត្រានេះ។

៧- ភាគីនីមួយៗត្រូវ នៅពេលសមស្រប អនុម័ត និងអនុវត្តច្បាប់ និងលិខិតបទដ្ឋាន ឬវិធានការផ្សេងទៀត ដើម្បីហាមឃាត់ការលក់ផលិតផលថ្នាំជក់ ដោយជនដែលមានអាយុក្រោមអាយុកំណត់ដោយច្បាប់មូលដ្ឋាន ច្បាប់ជាតិ ឬអាយុក្រោម១៨ ឆ្នាំ ។

### មាត្រា ១៧

### ការឧបត្ថម្ភចំពោះសកម្មភាពជំនួសដែលអាចធ្វើអោយរស់បាន

ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក និងជាមួយអង្គការអន្តររដ្ឋាភិបាល អន្តរជាតិ និងតំបន់ ដើម្បីជំរុញ នៅពេលសមស្របអោយមានការងារជំនួសដែលអាចចិញ្ចឹមជីវិតបានទៅកម្មករធ្វើការជាមួយថ្នាំជក់ អ្នកដាំថ្នាំជក់ ហើយនិងអាចដល់អ្នកលក់រាយផងដែរ។

## ផ្នែកទី ៥

## ការការពារបរិស្ថាន

### មាត្រា ១៨

### ការការពារបរិស្ថាន និងសុខភាពប្រជាជន

ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ភាគីទាំងឡាយយល់ព្រមការពារបរិស្ថាន និងសុខភាពរបស់ប្រជាពលរដ្ឋទាក់ទងនឹងបរិស្ថាន ចំពោះការដាំ និងផលិតថ្នាំជក់នៅក្នុងទឹកដីរបស់ខ្លួន។

## ផ្នែកទី ៦

## បញ្ហាទាក់ទងទៅនឹងការទទួលខុសត្រូវ

### មាត្រា ១៩

### ការទទួលខុសត្រូវ

១- សំរាប់គោលបំណងនៃការត្រួតពិនិត្យថ្នាំជក់ ភាគីទាំងឡាយត្រូវពិចារណាក្នុងការតាក់តែងច្បាប់ ឬជំរុញនូវការអនុវត្តច្បាប់ដែលមានស្រាប់របស់ខ្លួនក្នុងពេលចាំបាច់ ដើម្បីដោះស្រាយបញ្ហាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី រាប់បញ្ចូលទាំងការសងជម្ងឺចិត្ត នៅពេលសមស្រប។

២- អនុលោមតាមមាត្រា ២១ ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការក្នុងការប្តូរព័ត៌មានគ្នាទៅវិញទៅមក តាមរយៈសន្និសីទភាគី ប្តូរព័ត៌មានទាំងនោះរួមមាន :

(ក) ព័ត៌មានស្តីពីការប៉ះពាល់ដល់សុខភាពនៃការប្រើប្រាស់ផលិតផលថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ស្របតាមមាត្រា២០.៣ (ក)

(ខ) ព័ត៌មានស្តីពីច្បាប់ និងបទបញ្ជាជាធរមានក៏ដូចជាយុត្តិសាស្ត្រផងដែរ។

៣- ភាគីទាំងឡាយត្រូវ នៅពេលសមស្រប និងមានការព្រមព្រៀងគ្នានៅក្នុងក្របខ័ណ្ឌនៃច្បាប់ គោលនយោបាយ ការអនុវត្តច្បាប់ជាតិ និងសន្ធិសញ្ញាជាធរមាន ត្រូវជួយគ្នាទៅវិញទៅមកក្នុងដំណើររឿងក្តីទាក់ទងដល់ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដែលស៊ីសង្វាក់គ្នាជាមួយនិងអនុសញ្ញា។

៤- អនុសញ្ញាមិនត្រូវមានផលប៉ះពាល់ ឬក៏រិតសិទ្ធិរបស់ភាគីទាំងឡាយ ក្នុងការទៅប្តឹងដល់តុលាការរបស់ភាគីផ្សេងទៀត នៅពេលណាដែលភាគីទាំងនោះមានសិទ្ធិ។

៥- សន្និសីទភាគីអាចពិចារណា បើសិនជាអាចធ្វើទៅបាន នៅដើមដំបូងនៃដំណើរការ ដោយយកចិត្តទុកដាក់ចំពោះការងារដែលបានធ្វើរួចមកហើយនៅក្នុងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធ លើបញ្ហាទាក់ទងដល់ការទទួលខុសត្រូវ រួមបញ្ចូលទាំងការដោះស្រាយអន្តរជាតិសមស្របចំពោះបញ្ហានោះ ហើយនិងមធ្យោបាយសមស្របដើម្បីគាំទ្រ តាមការស្នើឧបត្ថម្ភគាំទ្រភាគីទាំងឡាយណានៅក្នុងច្បាប់របស់ខ្លួន ហើយនិងសកម្មភាពផ្សេងទៀត ស្របទៅតាមមាត្រានេះ។

## ផ្នែកទី ៧

## ការសហប្រតិបត្តិការ វិទ្យាសាស្ត្រ បច្ចេកទេស និងគមនាគមន៍ព័ត៌មាន

### មាត្រា ២០

### ការស្រាវជ្រាវ ការឃ្លាំមើល និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន

១- ភាគីទាំងឡាយត្រូវអភិវឌ្ឍ និងជំរុញការស្រាវជ្រាវថ្នាក់ជាតិ និងការសម្របសម្រួលនូវកម្មវិធីស្រាវជ្រាវនៅក្នុងតំបន់ ហើយនិងនៅកំរិតអន្តរជាតិ ក្នុងវិស័យត្រួតពិនិត្យថ្នាំជក់ ។

ដើម្បីសំរេចកិច្ចការនេះភាគីនីមួយៗត្រូវ :

(ក) ផ្តួចផ្តើម និងសហការដោយផ្ទាល់ ឬតាមរយៈអង្គការអន្តររដ្ឋាភិបាល អន្តរជាតិ និងតំបន់ ហើយនិងអង្គការផ្សេងទៀត ផ្តួចផ្តើមការស្រាវជ្រាវ និងការវាយតម្លៃវិទ្យាសាស្ត្រ និងជំរុញ និងលើកទឹកចិត្តដល់ការស្រាវជ្រាវដែលផ្តោតទៅលើមូលហេតុ និងផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ក៏ដូចជាការស្រាវជ្រាវ ដើម្បីកំណត់នូវដំណាំជំនួស

(ខ) ជំរុញ និងពង្រឹង ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការអន្តររដ្ឋាភិបាល អន្តរជាតិ និងតំបន់ ឬអង្គការផ្សេងទៀត ធ្វើការបណ្តុះបណ្តាល និងឧបត្ថម្ភគាំទ្រចំពោះសកម្មភាពទាក់ទងនឹងការត្រួតពិនិត្យថ្នាំជក់ រាប់បញ្ចូលទាំងការស្រាវជ្រាវ ការអនុវត្តន៍ និងការវាយតម្លៃ។

២- ភាគីទាំងឡាយ ត្រូវបង្កើតនៅពេលសមស្របនូវកម្មវិធីសំរាប់កំរិតជាតិ កំរិតតំបន់ និងការឃ្លាំមើលជាសកលនូវទំហំ លំនាំ មូលហេតុ និងផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់។ ដើម្បីសំរេចកិច្ចការនេះ ភាគីទាំងឡាយត្រូវបញ្ចូលកម្មវិធីឃ្លាំមើលថ្នាំជក់រួម នៅក្នុងកម្មវិធីឃ្លាំមើលសុខភាពកំរិតជាតិ កំរិតតំបន់ និងជាសកល។ ធ្វើយ៉ាងនេះទិន្នន័យអាចនឹងប្រៀបធៀប ហើយនិងអាចត្រូវបានធ្វើការវិភាគនៅកំរិតតំបន់ និងកំរិតអន្តរជាតិ នៅពេលសមស្រប។

៣- ភាគីទាំងឡាយទទួលស្គាល់សារសំខាន់នៃជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការអន្តររដ្ឋាភិបាល កំរិតអន្តរជាតិ និងតំបន់ និងអង្គការផ្សេងទៀត។ ភាគីនីមួយៗត្រូវខិតខំ :

(ក) បង្កើតបន្តិចម្តងៗនូវប្រព័ន្ធថ្នាក់ជាតិដើម្បីឃ្លាំមើលការរីករាលដាលនៃការប្រើប្រាស់ថ្នាំជក់ និងការពាក់ព័ន្ធដល់សង្គមកិច្ច សេដ្ឋកិច្ច និងសូចនាករសុខភាព

(ខ) ធ្វើសហប្រតិបត្តិការជាមួយនិងអង្គការអន្តររដ្ឋាភិបាល កំរិតអន្តរជាតិ និងតំបន់ និងអង្គការផ្សេងទៀត រួមបញ្ចូលទាំងភ្នាក់ងាររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ទៅក្នុងការឃ្លាំមើលថ្នាំជក់នៅកំរិតតំបន់ និងជាសកល និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មានស្តីពីសូចនាករដូចមានចែងក្នុងវាក្យខ័ណ្ឌ ៣(ក) នៃមាត្រានេះ

(គ) ធ្វើសហប្រតិបត្តិការជាមួយអង្គការសុខភាពពិភពលោកក្នុងការអភិវឌ្ឍន៍នូវសេចក្តីណែនាំជាទូទៅ ឬនីតិវិធីដើម្បីនឹងកំណត់អោយច្បាស់លាស់ចំពោះការប្រមូល ការវិភាគ និងការផ្សព្វផ្សាយនូវទិន្នន័យទាក់ទងដល់ការឃ្លាំមើលថ្នាំជក់ ។

៤- ភាគីទាំងឡាយ ត្រូវស្របតាមច្បាប់ជាតិ ជំរុញនិងសម្រួលការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មានវិទ្យាសាស្ត្រ បច្ចេកទេស សង្គមកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម និងច្បាប់ ក៏ដូចជាព័ត៌មានស្តីពីទម្លាប់របស់ឧស្សាហកម្មថ្នាំជក់ និងការដាំដុះថ្នាំជក់ ដែលពាក់ព័ន្ធនឹងអនុសញ្ញានេះ ហើយត្រូវយកចិត្តទុកដាក់និងផ្តោតទៅលើតម្រូវការពិសេសរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព។ ភាគីនីមួយៗត្រូវខិតខំ :

(ក) បង្កើតបន្តិចម្តងៗ និងរក្សានូវទិន្នន័យទាន់សម័យនៃច្បាប់ និងលិខិតបទដ្ឋានស្តីពីការត្រួតពិនិត្យថ្នាំជក់ នៅពេលសមស្រប ព័ត៌មានស្តីពីការអនុវត្តក៏ដូចជាយុទ្ធសាស្ត្រ និងធ្វើសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍កម្មវិធី សំរាប់ការត្រួតពិនិត្យថ្នាំជក់គ្រប់តំបន់ និងជាសកល

(ខ) បង្កើតបន្តិចម្តងៗ និងថែរក្សានូវទិន្នន័យទាន់សម័យបានមកពីកម្មវិធីឃ្លាំមើលគ្រប់ជាតិ ស្របទៅតាមវាក្យខ័ណ្ឌ ៣(ក) នៃមាត្រានេះ

(គ) ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីបង្កើតបន្តិចម្តងៗ និងថែរក្សាប្រព័ន្ធជាសកលមួយ ដើម្បីប្រមូលតាមពេលកំណត់ និងផ្សព្វផ្សាយព័ត៌មានស្តីពីការផលិតថ្នាំជក់ និងសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ដែលមានផលប៉ះពាល់ដល់អនុសញ្ញា ឬសកម្មភាពជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់ ។

៥- ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការនៅក្នុងអង្គការអន្តររដ្ឋាភិបាល គ្រប់តំបន់ និងអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុ និងអភិវឌ្ឍន៍ដែលខ្លួនជាសមាជិក ដើម្បីជំរុញ និងលើកទឹកចិត្តចំពោះការផ្តល់ធនធាន បច្ចេកទេស និងហិរញ្ញវត្ថុទៅលេខាធិការដ្ឋានដើម្បីជួយភាគីជាប្រទេសកំពុងអភិវឌ្ឍ និង ភាគីដែលមានសេដ្ឋកិច្ចនៅក្នុងអន្តរភាពឱ្យឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការធ្វើការស្រាវជ្រាវ ការឃ្លាំមើល និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន។

## មាត្រា ២១

## ការធ្វើរបាយការណ៍ និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន

១- ភាគីនីមួយៗ ត្រូវដាក់ជូនសន្និសីទភាគីតាមរយៈលេខាធិការដ្ឋាននូវរបាយការណ៍តាមពេលកំណត់ ស្តីពីការអនុវត្តន៍អនុសញ្ញានេះ ដែលនៅក្នុងនោះត្រូវមានបញ្ចូលនូវព័ត៌មានដូចខាងក្រោម :

(ក) ព័ត៌មានស្តីពីច្បាប់ លិខិតបទដ្ឋាន ឬវិធានការផ្សេងទៀត សំដៅអភិវឌ្ឍអនុសញ្ញា

(ខ) ព័ត៌មានសមស្របស្តីពីឧបសគ្គ ឬការរារាំង ដែលបានជួបប្រទះនូវក្នុងការអនុវត្តអនុសញ្ញា ហើយនិងវិធានការដែលបានចាត់ឡើង ដើម្បីនឹងបំបាត់នូវការរារាំងនោះ

(គ) ព័ត៌មានសមស្របស្តីពីជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស ដែលបានផ្តល់ ឬដែលបានទទួលសំរាប់សកម្មភាពត្រួតពិនិត្យថ្នាំជក់

(ឃ) ព័ត៌មានស្តីពីការឃ្លាំមើល និងការស្រាវជ្រាវដូចមានចែងនៅក្នុងមាត្រា ២០

(ង) ព័ត៌មានចែងក្នុងមាត្រា ៦.៣ . ១៣.២. ១៣.៣ . ១៣.៤ (ឃ). ១៥.៥ និង ១៩.២ ។

២- សង្វាក់ និងទម្រង់នៃរបាយការណ៍ធ្វើដោយភាគីទាំងអស់នោះ ត្រូវតែបានកំណត់ដោយសន្និសីទភាគី។ ភាគីនីមួយៗត្រូវធ្វើរបាយការណ៍ទី១ ក្នុងរយៈពេល ២ ឆ្នាំ បន្ទាប់ពីការចូលជាធរមានរបស់អនុសញ្ញាសំរាប់ភាគីនោះ ។

៣- សន្និសីទភាគី អនុលោមតាមមាត្រា ២២ និង ២៦ ត្រូវពិចារណាករមធ្យោបាយដើម្បីជួយភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព ទៅតាមសំណូមពរ ក្នុងការឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមមាត្រានេះ។

៤- ការធ្វើរបាយការណ៍ និងការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន អនុលោមទៅតាមអនុសញ្ញា ត្រូវគោរពទៅតាមច្បាប់របស់ជាតិពាក់ព័ន្ធនឹងការសម្ងាត់ និងជីវិតឯកជន។ ភាគីទាំងឡាយត្រូវការពារ តាមការព្រមព្រៀងគ្នាទៅវិញទៅមក នូវភាពសម្ងាត់របស់ព័ត៌មានដែលបានប្តូរគ្នាទៅវិញទៅមក។

## មាត្រា ២២

## ការសហប្រតិបត្តិការក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស និងច្បាប់ ហើយនិងការផ្តល់នូវឯកសារពាក់ព័ន្ធ

១- ភាគីទាំងឡាយត្រូវសហការដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការបំពេញកាតព្វកិច្ច ដែលលើកឡើងនៅក្នុងអនុសញ្ញា ដោយយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព។ កិច្ចសហប្រតិបត្តិការនេះ ត្រូវជំរុញការផ្ទេរនូវឯកទេសផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងច្បាប់ ហើយនិងបច្ចេកវិទ្យាតាមការព្រមព្រៀងគ្នាទៅវិញទៅមក ដើម្បីបង្កើត និងពង្រឹងយុទ្ធសាស្ត្រ ផែនការ និងកម្មវិធីត្រួតពិនិត្យថ្នាំជក់ថ្នាក់ជាតិ សំដៅ :

(ក) សម្រួលការអភិវឌ្ឍន៍ ការផ្ទេរ និងលទ្ធកម្មបច្ចេកវិទ្យា ចំណេះដឹង បច្ចេកទេស សមត្ថភាព និងឯកទេសពាក់ព័ន្ធនឹងការត្រួតពិនិត្យថ្នាំជក់

(ខ) ផ្តល់នូវឯកទេស បច្ចេកទេស វិទ្យាសាស្ត្រ ច្បាប់ និងឯកទេសដទៃទៀតដើម្បីបង្កើត និងពង្រឹងយុទ្ធសាស្ត្រ ផែនការ និងកម្មវិធីជាតិ ដើម្បីត្រួតពិនិត្យថ្នាំជក់ សំដៅធ្វើការអនុវត្តន៍អនុសញ្ញា តាមរយៈ :

i) ការជួយ តាមសំណើ ការអភិវឌ្ឍន៍នូវគ្រឹះច្បាប់មួយដ៏រឹងមាំ ក៏ដូចជាកម្មវិធីបច្ចេកទេស រួមបញ្ចូលទាំងកម្មវិធីបង្ការការនាំអាទិ៍ ការជំរុញអោយឈប់ និងការការពារការរងផ្សែងថ្នាំជក់

ii) ការជួយសមស្របដល់អ្នកធ្វើការជាមួយថ្នាំជក់ ក្នុងការអភិវឌ្ឍន៍នូវរបៀបរស់នៅជំនួសសមស្របតាមផ្លូវសេដ្ឋកិច្ច និងផ្លូវច្បាប់ នៅក្នុងរបៀបមួយអាចទទួលយកបាន

iii) ការជួយសមស្របដល់អ្នកដាំថ្នាំជក់ ក្នុងការប្តូរផលិតផលកសិកម្មទៅការដាំដុះជំនួសមួយដែលអាចទទួលយកបាន

(គ) ឧបត្ថម្ភគាំទ្រនូវការបណ្តុះបណ្តាលសមស្រប ឬកម្មវិធីបញ្ចុះបញ្ចូលសំរាប់បុគ្គលិកសមស្រប អនុលោមទៅតាមមាត្រា ១២

(ឃ) ការផ្តល់សមស្របដល់តម្រូវការជាសម្ភារៈ បរិក្ខារ ពូជ ក៏ដូចជាការឧបត្ថម្ភគាំទ្រដល់ទីតាំង ដើម្បីយុទ្ធសាស្ត្រ ផែនការនៃកម្មវិធីត្រួតពិនិត្យថ្នាំជក់

(ង) ការកំណត់វិធីត្រួតពិនិត្យថ្នាំជក់ រួមបញ្ចូលទាំងការព្យាបាលដ៏ទូលំទូលាយចំពោះការញៀននីកូទីន ។

២- សន្និសីទភាគីត្រូវជំរុញ និងសម្រួលការផ្ទេរនូវឯកទេស បច្ចេកទេស វិទ្យាសាស្ត្រ ច្បាប់ និងបច្ចេកវិទ្យា ដោយធានាអោយមានការគាំទ្រហិរញ្ញវត្ថុ អនុលោមទៅតាមមាត្រា ២៦។

## ផ្នែកទី ៨
## ការរៀបចំស្ថាប័ន និងធនធានហិរញ្ញវត្ថុ

### មាត្រា ២៣
### សន្និសីទភាគី

១- សន្និសីទភាគីមួយ ត្រូវបានបង្កើត។ កិច្ចប្រជុំទីមួយនៃសន្និសីទ ត្រូវបានកោះប្រជុំដោយអង្គការសុខភាពពិភពលោក កុំអោយយឺតជាងមួយឆ្នាំបន្ទាប់ពីការចូលជាធរមានរបស់អនុសញ្ញានេះ សន្និសីទនឹងកំណត់ទីកន្លែង និងពេលវេលាសំរាប់កិច្ចប្រជុំធម្មតាបន្តបន្ទាប់ពីកិច្ចប្រជុំទីមួយនេះ ។

២- កិច្ចប្រជុំវិសាមញ្ញនៃសន្និសីទភាគីត្រូវប្រារព្ធទៅពេលណាមួយដទៃទៀត នៅពេលដែលសន្និសីទមានការចាំបាច់ ឬតាមសំណើជាលាយលក្ខអក្សររបស់ភាគីណាមួយ អោយតែក្នុងរយៈពេល ៦ ខែ បន្ទាប់ពីសំណើត្រូវបានជូនដំណឹងទៅភាគីដទៃទៀត ដោយលេខាធិការដ្ឋានរបស់អនុសញ្ញា មានគាំទ្រដោយយ៉ាងតិចមួយភាគបីនៃភាគី ។

៣- សន្និសីទភាគីត្រូវអនុម័តដោយកុងសង់ស៊ីសលើលក្ខន្តិកៈផ្ទៃក្នុងនៅកិច្ចប្រជុំលើកទីមួយ ។

៤- សន្និបាតភាគីត្រូវអនុម័តដោយកុងសង់ស៊ីសនូវវិធានហិរញ្ញវត្ថុរបស់ខ្លួន ក៏ដូចជាការគ្រប់គ្រងនូវមូលនិធិរបស់អង្គការរណប ដែលសន្និសីទអាចបង្កើត ក៏ដូចជាការផ្តល់នូវហិរញ្ញវត្ថុ ដើម្បីការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាន។ នៅកិច្ចប្រជុំសាមញ្ញនីមួយៗ ត្រូវតែមានការអនុម័តនូវថវិកាមួយសំរាប់រយៈពេលហិរញ្ញវត្ថុ រហូតដល់កិច្ចប្រជុំសាមញ្ញបន្ទាប់។

៥- សន្និសីទភាគីត្រូវរក្សានូវការពិនិត្យជារឿយៗនូវការអនុវត្តន៍អនុសញ្ញា និងធ្វើសេចក្តីសំរេចចាំបាច់សំរាប់ជំរុញការអនុវត្តន៍អោយមានប្រសិទ្ធភាព និងអាចអនុម័តពិធីសារ ឧបសម្ព័ន្ធ និងវិសោធនកម្មអនុសញ្ញា អនុលោមតាមមាត្រា ២៨ ២៩ និង ៣៣ ដើម្បីសំរេចនូវកិច្ចការនេះ សន្និសីទត្រូវ :

(ក) ជំរុញ និងសម្រួលការប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន អនុលោមតាមមាត្រា ២០ និងមាត្រា ២១

(ខ) ជំរុញ និងដឹកនាំការអភិវឌ្ឍន៍ និងការធ្វើអោយប្រសើរឡើង តាមពេលកំណត់ នូវវិធីសាស្ត្រប្រហាក់ប្រហែលគ្នា ដើម្បីការស្រាវជ្រាវ និងការប្រមូលទិន្នន័យបន្ថែមទៅលើអ្វីដែលមានចែងនៅក្នុងមាត្រា ២០ ពាក់ព័ន្ធដល់ការអនុវត្តន៍អនុសញ្ញា

(គ) ជំរុញ តាមការសមស្រប នូវការអភិវឌ្ឍន៍ ការអនុវត្តន៍ ការវាយតម្លៃនៃយុទ្ធសាស្ត្រ ផែនការ និងកម្មវិធី ក៏ដូចជាគោលនយោបាយ នីតិកម្ម និងវិធានការផ្សេងទៀត

(ឃ) ពិចារណាលើរបាយការណ៍ដាក់ជូនដោយភាគី អនុលោមតាមមាត្រា ២១ និងអនុម័តរបាយការណ៍ធម្មតាស្តីពីការអនុវត្តន៍អនុសញ្ញា

(ង) ជំរុញ និងសម្រួលការកៀងគរធនធានហិរញ្ញវត្ថុសំរាប់ការអនុវត្តន៍អនុសញ្ញា អនុលោមតាមមាត្រា ២៦

(ច) បង្កើតនូវអង្គការរណបដែលចាំបាច់សំរាប់សំរេចនូវគោលដៅរបស់អនុសញ្ញា

(ឆ) ស្នើសុំពេលណាសមស្រប នូវសេវា និងការសហប្រតិបត្តិការ និងព័ត៌មានផ្តល់ដោយអង្គការពាក់ព័ន្ធ និងមានសមត្ថកិច្ច និងអង្គការនៃប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាល ក៏តែអន្តរជាតិ និងតំបន់ដទៃទៀត និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការដែលជាមធ្យោបាយសំរាប់ពង្រឹងការអនុវត្តន៍អនុសញ្ញា

(ជ) ពិចារណាលើសកម្មភាពផ្សេងទៀត តាមការសមស្រប ដើម្បីសំរេចនូវគោលដៅរបស់អនុសញ្ញា ទៅតាមបទពិសោធន៍បានមកពីការអនុវត្តរបស់ខ្លួន ។

៦- សន្និសីទភាគី ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យសំរាប់ការចូលរួមរបស់អ្នកសង្កេតការណ៍ក្នុងដំណើររឿងរបស់ខ្លួន ។

## មាត្រា ២៤

## លេខាធិការដ្ឋាន

១- សន្និសីទភាគីត្រូវតែងតាំងលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ និងរៀបចំការប្រព្រឹត្តិទៅរបស់វា ។ សន្និសីទភាគីត្រូវខិតខំខ្នះខ្នែងធ្វើអោយបាននៅពេលកិច្ចប្រជុំទីមួយរបស់ខ្លួន ។

២- រហូតដល់ពេលដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយត្រូវបានតែងតាំង និងបង្កើតឡើង មុខងាររបស់លេខាធិការ-ដ្ឋាននៃអនុសញ្ញាត្រូវបានផ្តល់អោយដោយអង្គការសុខភាពពិភពលោក ។

៣- មុខងាររបស់លេខាធិការដ្ឋានគឺ :

(ក) រៀបចំកិច្ចប្រជុំសំរាប់សន្និសីទភាគី និងអង្គការរណបរបស់អនុសញ្ញា ហើយនិងផ្តល់សេវា ដែលសន្និសីទ និងអង្គការទាំងនោះត្រូវការ

(ខ) បញ្ជូននូវរបាយការណ៍ដែលខ្លួនបានទទួលអនុលោមតាមអនុសញ្ញា

(គ) ផ្តល់ការឧបត្ថម្ភគាំទ្រដល់ភាគី ជាពិសេសភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព តាមសំណើ ក្នុងការប្រមូល និងគមនាគមន៍ព័ត៌មានចាំបាច់ អនុលោមតាមបញ្ញត្តិនៃអនុសញ្ញា

(ឃ) រៀបចំរបាយការណ៍ស្តីពីសកម្មភាព ក្រោមអនុសញ្ញាតាមការណែនាំរបស់សន្និសីទទី២ ហើយដាក់របាយការណ៍ទាំងនោះ ជូនទៅសន្និសីទភាគី

(ង) ធានាតាមការណែនាំរបស់សន្និសីទភាគីនូវការសម្របសម្រួលចាំបាច់ជាមួយអង្គការអន្តររដ្ឋាភិបាល អន្តរជាតិ និងតំបន់ដែលមានសមត្ថកិច្ច ហើយនិងអង្គការផ្សេងទៀត

(ច) បញ្ចូលតាមការណែនាំរបស់សន្និសីទភាគីទៅក្នុងការរៀបចំរដ្ឋបាល ឬ ជាប់កិច្ចសន្យា ដែលអាចជាការចាំបាច់ ដើម្បីបំពេញនូវមុខងាររបស់ខ្លួន

ឆ- បំពេញនូវមុខងារលេខាធិការដ្ឋានដទៃទៀតដែលមានចែងនៅក្នុងអនុសញ្ញា និងក្នុងពិធីសារ ហើយ មុខងារដទៃទាំងនោះ អាចត្រូវបានកំណត់ដោយសន្និសីទភាគី ។

## មាត្រា ២៥

## ទំនាក់ទំនងរវាងសន្និសីទភាគី និងអង្គការអន្តររដ្ឋាភិបាល

ដើម្បីនឹងផ្តល់នូវកិច្ចសហប្រតិបត្តិការបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់សំរេចនូវគោលដៅនៃអនុសញ្ញា សន្និសីទ-ភាគីអាចធ្វើសំណូមពរកិច្ចសហប្រតិបត្តិការពីអង្គការអន្តររដ្ឋាភិបាល គឺរិតអន្តរជាតិ និងតំបន់ដែលមានសមត្ថកិច្ច រាប់បញ្ចូលទាំងស្ថាប័នហិរញ្ញវត្ថុ និងអភិវឌ្ឍន៍ ។

## មាត្រា ២៦

## ធនធានហិរញ្ញវត្ថុ

១- ភាគីទាំងឡាយទទួលស្គាល់តួនាទីសំខាន់របស់ធនធានហិរញ្ញវត្ថុ ក្នុងការសំរេចនូវគោលដៅរបស់អនុសញ្ញានេះ ។

២- ភាគីនីមួយៗត្រូវផ្តល់ការឧបត្ថម្ភគាំទ្រជាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងសកម្មភាពនៃជាតិរបស់ខ្លួន ក្នុងគោលបំណងសំរេចនៃគោលដៅរបស់អនុសញ្ញា ស្របទៅតាមផែនការអាទិភាព និងកម្មវិធីជាតិរបស់ខ្លួន ។

៣- ភាគីទាំងឡាយត្រូវជំរុញ នៅពេលសមស្រប នូវការប្រើបណ្តាញទ្វេភាគី តំបន់ អនុតំបន់ និងពហុភាគី ដទៃទៀត ដើម្បីផ្តល់មូលនិធិសំរាប់ការអភិវឌ្ឍ និងពង្រឹងកម្មវិធីទូលំទូលាយ ពហុភាគីនៃការត្រួតពិនិត្យថ្នាំជក់ របស់ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព ការផលិតជំនួសការផលិតថ្នាំជក់ ដែលអាចចិញ្ចឹមជីវិតបាន រាប់បញ្ចូលទាំងការដាំដុះធញ្ញជាតិផ្សេងទៀត ត្រូវតែយកមកដោះស្រាយ និងឧបត្ថម្ភគាំទ្រ នៅក្នុងបរិបទនៃយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍ដែលមាននិរន្តរភាពរបស់ប្រទេស ។

៤- ភាគីទាំងឡាយដែលជាតំណាងនៅក្នុងអង្គការអន្តររដ្ឋាភិបាលគឺរិតតំបន់ និងគឺរិតអន្តរជាតិពាក់ព័ន្ធ និងស្ថាប័នហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ ត្រូវលើកទឹកចិត្តអង្គការទាំងនោះអោយផ្តល់ជំនួយហិរញ្ញវត្ថុដល់ភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព ដើម្បីជួយភាគីទាំងនោះ អោយបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញា ដោយពុំមានគឺរិតនូវសិទ្ធិចូលរួមនៅក្នុងអង្គការទាំងនោះឡើយ ។

៥- ភាគីទាំងឡាយយល់ព្រមថា :

(ក) នឹងជួយភាគីអោយបំពេញកាតព្វកិច្ចរបស់ខ្លួន នៅក្រោមអនុសញ្ញានូវរាល់ធនធាន ហិរញ្ញវត្ថុ បច្ចេក-ទេស និងអ្វីផ្សេងទៀតដែលមានស្រាប់ ឬសក្តានុភូត ទាំងសាធារណៈ និងឯកជនដែលមានសំរាប់សកម្មភាពត្រួតពិនិត្យថ្នាំជក់ ត្រូវតែបានកៀងគរ និងប្រើប្រាស់សំរាប់ជាផលប្រយោជន៍របស់ភាគីទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព

## ជំពូកទី ១០

## ការវិវត្តន៍នៃអនុសញ្ញា

### មាត្រា ២៨

### វិសោធនកម្មនៃអនុសញ្ញានេះ

១- ភាគីណាក៏ដោយអាចធ្វើសំណូមពរវិសោធនកម្មលើអនុសញ្ញានេះ។ វិសោធនកម្មនេះ នឹងត្រូវពិចារណាដោយសន្និសីទភាគី។

២- វិសោធនកម្មនៃអនុសញ្ញាត្រូវតែអនុម័តដោយសន្និសីទភាគី អត្ថបទនៃសំណើវិសោធនកម្មអនុសញ្ញាណាមួយក៏ត្រូវតែជូនដំណឹងទៅភាគីទាំងឡាយ ដោយលេខាធិការដ្ឋានយ៉ាងតិច ៦ ខែ មុននឹងកិច្ចប្រជុំ ដែលត្រូវអនុម័តនូវសំណើវិសោធនកម្មនេះប្រារព្ធធ្វើឡើង។ លេខាធិការដ្ឋានក៏ត្រូវជូនដំណឹងអំពីសំណើ វិសោធនកម្មទៅហត្ថលេខីទាំងឡាយនៃអនុសញ្ញា ហើយជាព័ត៌មានទៅអ្នកទទួលបញ្ញើ។

៣- ភាគីទាំងឡាយ ត្រូវខិតខំ ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងដោយកុងសង់ស៊ុសលើសំណើវិសោធនកម្មអនុសញ្ញា។ បើការប្រឹងប្រែងដើម្បីរកកុងសង់ស៊ុស ត្រូវបញ្ចប់ទៅហើយ តែពុំបានឈានទៅដល់ការព្រមព្រៀងទេ វិសោធនកម្មត្រូវ តាមរយៈមធ្យោបាយចុងក្រោយបំផុត តែអនុម័តដោយ ៣/៤ (បីភាគបួន) នៃសម្លេងភាគីវត្តមាននិងមានអំណាចបោះឆ្នោតនៅក្នុងកិច្ចប្រជុំ។ ក្នុងគោលបំណងសំរាប់មាត្រានេះ ភាគីវត្តមាននិងមានអំណាចបោះឆ្នោត មានន័យថា ជាភាគីវត្តមាន និងអាចបោះឆ្នោតយល់ព្រម ឬមិនយល់ព្រម។ វិសោធនកម្មដែលត្រូវបានអនុម័ត ត្រូវតែជូនដំណឹងដោយលេខាធិការដ្ឋានទៅអ្នកទទួលបញ្ញើ ដែលជាអ្នកបញ្ជូនឯកសារនោះ ទៅភាគីទាំងអស់ដើម្បីសុំការឯកភាព។

៤- លិខិតូបករណ៍ឯកភាពទាក់ទងនឹងវិសោធនកម្ម ត្រូវតែតម្កល់ទុកនៅជាមួយអ្នកដែលទទួលបញ្ញើ។ វិសោធនកម្មដែលបានទទួលការអនុម័តមួយ ដែលស្របទៅតាមវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ត្រូវចូលជាធរមាន សំរាប់ភាគីដែលឯកភាពទាំងនោះ ក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃទទួលលិខិតូបករណ៍ឯកភាពយ៉ាងតិច ២/៣ (ពីរភាគបី) នៃភាគីអនុសញ្ញា ដោយអ្នកទទួលបញ្ញើ។

៥- វិសោធនកម្មត្រូវចូលជាធរមានសំរាប់ភាគីដទៃទៀតក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលភាគីនោះ បានតម្កល់លិខិតូបករណ៍ឯកភាពទៅលើវិសោធនកម្មនោះជាមួយអ្នកទទួលបញ្ញើ។

### មាត្រា ២៩

### ការអនុម័ត និងវិសោធនកម្មលើឧបសម្ព័ន្ធនៃអនុសញ្ញានេះ

១- ឧបសម្ព័ន្ធនៃអនុសញ្ញានេះនឹងវិសោធនកម្ម ត្រូវតែស្នើ អនុម័តនិងចូលជាធរមាន អនុលោមតាមនីតិវិធីដូចមានចែងនៅក្នុងមាត្រា ២៨។

២- ឧបសម្ព័ន្ធនៃអនុសញ្ញា ត្រូវចាត់ទុកជាចំណែកនៃអនុសញ្ញា ហើយលើកលែងតែមានការចែងយ៉ាងច្បាស់លាស់ផ្សេងពីនេះ ការយោងទៅលើអនុសញ្ញា គឺជាការយោង នៅពេលជាមួយគ្នា ទៅលើឧបសម្ព័ន្ធទាំងអស់នៃអនុសញ្ញា ។

៣- ឧបសម្ព័ន្ធត្រូវបានកម្រិតនៅក្នុងបញ្ជី ទម្រង់ និងសម្ភារៈពិពណ៌នាដទៃទៀតទាក់ទងនឹងបញ្ហានីតិវិធី វិទ្យាសាស្ត្របច្ចេកទេស ឬរដ្ឋបាល ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

### មាត្រា ៣០

### ការរក្សាសិទ្ធិមិនទាន់សំរេច

ការរក្សាសិទ្ធិមិនទាន់សំរេចមិនអាចធ្វើបានទេសំរាប់អនុសញ្ញានេះ ។

### មាត្រា ៣១

### ការសុំដកខ្លួនចេញ

១- នៅពេលណាមួយក៏ដោយ ក្រោយពី ២ ឆ្នាំ បន្ទាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីមួយភាគីនោះ អាចសុំដកខ្លួនចេញពីអនុសញ្ញា ដោយផ្តល់ការជូនដំណឹងជាលាយលក្ខអក្សរទៅអ្នកទទួលបញ្ញើ ។

២- ការសុំដកខ្លួនចេញនេះ ត្រូវមានសុពលភាពចាប់ពី ១ ឆ្នាំ បន្ទាប់ពីថ្ងៃដែលអ្នកទទួលបញ្ញើបានទទួលសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញ ឬនៅថ្ងៃក្រោយជាងនេះទៀត ដូចមានចែងជាក់លាក់នៅក្នុងសេចក្តីជូនដំណឹងដកខ្លួនចេញ ។

៣- ភាគីណាដែលដកខ្លួនចេញពីអនុសញ្ញា ត្រូវបានសទុកថា បានដកខ្លួនចេញពីពិធីសារដែលភាគីនោះជាហត្ថលេខីផងដែរ ។

### មាត្រា ៣២

### សិទ្ធិបោះឆ្នោត

១- ភាគីនីមួយៗនៃអនុសញ្ញា ត្រូវមាន ១ សម្លេង លើកលែងតែមានចែងនៅក្នុងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

២- ចំពោះបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវបំពេញសិទ្ធិបោះឆ្នោតដោយមានចំនួនសំលេងស្មើនឹងចំនួនសំលេងនៃរដ្ឋសមាជិករបស់ខ្លួនដែលជាភាគីនៃអនុសញ្ញា។ អង្គការនោះមិនត្រូវបំពេញសិទ្ធិបោះឆ្នោតរបស់ខ្លួនទេ បើសិនជារដ្ឋជាសមាជិករបស់ខ្លួនណាមួយបំពេញនូវសិទ្ធិរបស់ខ្លួនរួចហើយ និងផ្ទុយមកវិញ ។

២- ឧបសម្ព័ន្ធនៃអនុសញ្ញា ត្រូវចាត់ទុកជាចំណែកនៃអនុសញ្ញា ហើយលើកលែងតែមានការចែងយ៉ាងច្បាស់លាស់ផ្សេងពីនេះ ការយោងទៅលើអនុសញ្ញា គឺជាការយោង នៅពេលជាមួយគ្នា ទៅលើឧបសម្ព័ន្ធទាំងអស់នៃអនុសញ្ញា។

៣- ឧបសម្ព័ន្ធត្រូវបានកម្រិតនៅក្នុងបញ្ជី ទម្រង់ និងសម្ភារៈពិពណ៌នាដទៃទៀតទាក់ទងនឹងបញ្ហានីតិវិធី វិទ្យាសាស្ត្របច្ចេកទេស ឬរដ្ឋបាល។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

### មាត្រា ៣០

### ការរក្សាសិទ្ធិមិនទាន់សំរេច

ការរក្សាសិទ្ធិមិនទាន់សំរេចមិនអាចធ្វើបានទេសំរាប់អនុសញ្ញានេះ ។

### មាត្រា ៣១

### ការសុំដកខ្លួនចេញ

១- នៅពេលណាមួយក៏ដោយ ក្រោយពី ២ ឆ្នាំ បន្ទាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីមួយ ភាគីនោះ អាចសុំដកខ្លួនចេញពីអនុសញ្ញា ដោយផ្តល់ការជូនដំណឹងជាលាយលក្ខអក្សរទៅអ្នកទទួលបញ្ជី។

២- ការសុំដកខ្លួនចេញនេះ ត្រូវមានសុពលភាពចាប់ពី ១ ឆ្នាំ បន្ទាប់ពីថ្ងៃដែលអ្នកទទួលបញ្ជីបានទទួលសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញ ឬនៅថ្ងៃក្រោយជាងនេះទៀត ដូចមានចែងជាក់លាក់នៅក្នុងសេចក្តីជូនដំណឹងដកខ្លួនចេញ។

៣- ភាគីណាដែលដកខ្លួនចេញពីអនុសញ្ញា ត្រូវបានសទុកថា បានដកខ្លួនចេញពីពិធីសារដែលភាគីនោះជាហត្ថលេខីផងដែរ។

### មាត្រា ៣២

### សិទ្ធិបោះឆ្នោត

១- ភាគីនីមួយៗនៃអនុសញ្ញា ត្រូវមាន ១ សម្លេង លើកលែងតែមានចែងនៅក្នុងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

២- ចំពោះបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវបំពេញសិទ្ធិបោះឆ្នោតដោយមានចំនួនសំលេងស្មើនឹងចំនួនសំលេងនៃរដ្ឋសមាជិករបស់ខ្លួនដែលជាភាគីនៃអនុសញ្ញា។ អង្គការនោះមិនត្រូវបំពេញសិទ្ធិបោះឆ្នោតរបស់ខ្លួនទេ បើសិនជារដ្ឋជាសមាជិករបស់ខ្លួនណាមួយបំពេញនូវសិទ្ធិរបស់ខ្លួនរួចហើយ និងផ្ទុយមកវិញ។

## មាត្រា ៣៣

## ពង្រាងពិធីសារ

១- ភាគីណាក៏ដោយ ក៏អាចស្នើនូវពិធីសារដែរ ។ ពិធីសារនោះនឹងត្រូវបានពិចារណាដោយសន្និសីទភាគី ។

២- សន្និសីទភាគីអាចអនុម័តពិធីសារនៃអនុសញ្ញា ។ ក្នុងការអនុម័តពិធីសារទាំងនោះ ការខិតខំដើម្បីរកកុងសង់ស៊ីសត្រូវតែធ្វើ ។ បើការខំប្រឹងប្រែងដើម្បីរកកុងសង់ស៊ីសពុំបានលទ្ធផល ហើយការព្រមព្រៀងមួយក៏ពុំបានសម្រេច ជាដំណោះស្រាយចុងក្រោយបង្អស់ ពិធីសារត្រូវតែអនុម័តដោយ ៣/៤ (បីភាគបួន) នៃសំលេងវត្តមាន និងមានអំណាចបោះឆ្នោតក្នុងកិច្ចប្រជុំ ។ ដើម្បីគោលបំណងនៃមាត្រានេះ ភាគីវត្តមាននឹងមានអំណាចបោះឆ្នោត មានន័យថា ជាភាគីវត្តមាននិងបោះឆ្នោតអាចយល់ព្រមឬមិនយល់ព្រម ។

៣- អត្ថបទនៃសំណើពិធីសារណាមួយក៏ដោយ ក៏ត្រូវតែជូនដំណឹងទៅអោយភាគីដោយលេខាធិការដ្ឋានយ៉ាងតិច ៦ ខែ មុនកិច្ចប្រជុំ ដែលពិធីសារនោះ ត្រូវបានស្នើមកសុំការអនុម័ត ។

៤- មានតែភាគីនៃអនុសញ្ញាទេ ដែលអាចជាភាគីនៃពិធីសារមួយ ។

៥- ពិធីសារណាមួយក៏ដោយនៃអនុសញ្ញា ត្រូវតែមានការភ្ជាប់កាតព្វកិច្ចចំពោះតែភាគីពាក់ព័ន្ធនៃពិធីសារតែប៉ុណ្ណោះ ។ មានតែភាគីនៃពិធីសារទេ ដែលអាចសំរេចលើបញ្ហាពាក់ព័ន្ធជាពិសេសទៅលើពិធីសារនោះ ។

៦- តម្រូវការសំរាប់ការចូលជាធរមានរបស់ពិធីសារមួយ ត្រូវតែបានបង្កើតឡើងដោយលិខិតូបករណ៍នោះ ។

## មាត្រា ៣៤

## ការចុះហត្ថលេខា

អនុសញ្ញានេះ ត្រូវបានបើកអោយចុះហត្ថលេខាដោយសមាជិកទាំងអស់នៃអង្គការសុខភាពពិភពលោក និងដោយរដ្ឋដែលពុំមែនជាសមាជិកនៃអង្គការសុខភាពពិភពលោក ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នៅទីស្នាក់ការកណ្តាលនៃអង្គការសុខភាពពិភពលោកនៅទីក្រុងហ្សឺណែវ ចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៣ និងបន្ទាប់មកនៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិនៅទីក្រុងញ៉ូវយ៉ក ចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៤ ។

## មាត្រា ៣៥

## ការផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការសុខចិត្តចូលជាសមាជិក

១- អនុសញ្ញានេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ឬការសុខចិត្តចូលជាសមាជិកដោយរដ្ឋ និងការបញ្ជាក់ជាផ្លូវការ ឬការសុខចិត្តចូលជាសមាជិកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ។ អនុសញ្ញាត្រូវតែបើកសំរាប់ការសុខចិត្តចូលជាសមាជិក ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដែលអនុសញ្ញានេះ ត្រូវបានបិទមិនអោយចុះហត្ថលេខា ។ លិខិតូប-

ករណីនៃការផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការសុខចិត្តចូលជាសមាជិក ត្រូវតែតម្កល់ជាមួយអ្នកទទួលបញ្ញើ ។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលក្លាយទៅជាភាគីនៃអនុសញ្ញា ដោយពុំមានរដ្ឋជាភាគីរបស់ខ្លួនណាមួយ ដែលជាភាគីនៃអនុសញ្ញាត្រូវជាប់កាតព្វកិច្ចទៅនឹងកាតព្វកិច្ចទាំងអស់នៅក្រោមអនុសញ្ញានេះ ។ បើរដ្ឋសមាជិកមួយ ឬច្រើននៃអង្គការទាំងនោះជាភាគីរបស់អនុសញ្ញា អង្គការ និងរដ្ឋជាសមាជិករបស់ខ្លួន ត្រូវសំរេចអំពីការទទួលខុសត្រូវរៀង១ខ្លួន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញា ។ ក្នុងករណីនេះ អង្គការនិងរដ្ឋជាសមាជិក មិនត្រូវមានតួនាទីបំពេញនូវសិទ្ធិនៅក្រោមអនុសញ្ញានេះស្របគ្នាទេ ។

៣- អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវនៅក្នុងលិខិតូបករណ៍របស់ខ្លួនទាក់ទងទៅនឹងការបញ្ជាក់ជាផ្លូវការ ឬនៅក្នុងលិខិតូបករណ៍របស់ខ្លួនស្តីអំពីការសុខចិត្តចូលជាសមាជិក ប្រកាសអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងដោយអនុសញ្ញា ។ អង្គការទាំងនោះក៏ត្រូវជូនព័ត៌មានទៅអ្នកទទួលបញ្ញើ ដែលត្រូវជូនព័ត៌មានទៅភាគីទាំងឡាយ ចំពោះការផ្លាស់ប្តូរជាសំខាន់នៅក្នុងការពង្រីកវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ៣៦

## ការចូលជាធរមាន

១- អនុសញ្ញានេះត្រូវចូលជាធរមាននៅ ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់លិខិតូបករណ៍ទី ៤០ នៃការផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការសុខចិត្តចូលជាសមាជិក នៅកន្លែងអ្នកទទួលបញ្ញើ ។

២- ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ការយល់ព្រម ឬការឯកភាពលើអនុសញ្ញា ឬសុខចិត្តចូលជាសមាជិក បន្ទាប់ពីល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ សំរាប់ការចូលជាធរមាន ត្រូវបានបំពេញ អនុសញ្ញាត្រូវចូលជាធរមាន ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់លិខិតូបករណ៍របស់ខ្លួន ដើម្បីផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ឬការសុខចិត្តចូលជាសមាជិក ។

៣- សំរាប់អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នីមួយៗ ដែលបានតម្កល់លិខិតូបករណ៍សំរាប់ការបញ្ជាក់ជាផ្លូវការ ឬលិខិតូបករណ៍សំរាប់ការសុខចិត្តចូលជាសមាជិក បន្ទាប់ពីល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ សំរាប់ការចូលជាធរមានត្រូវបានបំពេញ អនុសញ្ញាត្រូវចូលជាធរមាន ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់លិខិតូបករណ៍សំរាប់ការបញ្ជាក់ជាផ្លូវការ ឬសំរាប់ការសុខចិត្តចូលជាសមាជិក ។

៤- សំរាប់គោលបំណងនៃមាត្រានេះ លិខិតូបករណ៍ដែលត្រូវបានតម្កល់ដោយអង្គការសហមារណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវរាប់ជាលិខិតបន្ថែមទៅលើលិខិតដែលបានតម្កល់ដោយរដ្ឋជាសមាជិកនៃអង្គការនោះទេ ។

## មាត្រា ៣៧

## ការទទួលបញ្ញើ

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ គឺជាអ្នកទទួលបញ្ញើសំរាប់អនុសញ្ញានេះ និងវិសោធនកម្ម ពិធីសារឧបសម្ព័ន្ធ ដែលត្រូវបានអនុម័តស្របតាមមាត្រា ២៨ ២៩ និងមាត្រា ៣៣ ។

## មាត្រា ៣៨

## អត្ថបទយថាភូត

ច្បាប់ដើមនៃអនុសញ្ញានេះ ដែលជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល ជាអត្ថបទយថាភូតដែលមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាពអ្នកដែលបានទទួលការអនុញ្ញាតត្រឹមត្រូវសំរាប់កិច្ចការនេះ បានចុះហត្ថលេខានៅលើអនុសញ្ញានៅខាងក្រោយនេះ ។

ធ្វើនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ។

## ឧបសម្ព័ន្ធទី ១

## WHA លេខ 56.1 អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់

មហាសន្និបាតទី ៥៦ ស្តីពីសុខភាពពិភពលោក

យោងសេចក្តីសំរេច WHA 49.17 និង WHA 52.18 ដែលអំពាវនាវសំរាប់ការអភិវឌ្ឍន៍អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ អនុលោមទៅតាមមាត្រា ១៩ នៃធម្មនុញ្ញអង្គការសុខភាពពិភពលោក។

ប្តេជ្ញាថានឹងការពារជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយប្រឆាំងនឹងការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ។

កត់សំគាល់ដោយមានការកង្វល់យ៉ាងខ្លាំងនូវការកើនឡើងនៃការជក់ និងរូបភាពផ្សេងទៀតនៃការប្រើថ្នាំជក់ទូទាំងសកលលោក ។

ទទួលស្គាល់ដោយអបអរសាទរនូវរបាយការណ៍របស់ប្រធាននៃអង្គការអន្តររដ្ឋាភិបាល ដើម្បីការចរចាស្តីពីលទ្ធផលនៃការងាររបស់អង្គការអន្តររដ្ឋាភិបាល។

ដោយជឿជាក់ថាអនុសញ្ញានេះ ជាជំហានដ៏សំខាន់មួយសំរាប់ជំរុញទៅមុខនូវសកម្មភាពជាតិ តំបន់ និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការជាសកល ដើម្បីការពារសុខភាពរបស់មនុស្សប្រឆាំងនឹងផលប៉ះពាល់ដ៏រីករាលដាលនៃការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់ ហើយគិតថា ការយកចិត្តទុកដាក់ជាពិសេសត្រូវតែបានផ្តល់អោយ ដល់ស្ថានភាពពិសេស របស់ប្រទេសដែលកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព។

សង្កត់ធ្ងន់ទៅលើតម្រូវការអោយមានការចូលជាធរមានដោយឆាប់បំផុត និងការអនុវត្តន៍ដោយប្រសិទ្ធភាពនៃអនុសញ្ញា

១- អនុម័តអនុសញ្ញាដែលភ្ជាប់មកជាមួយសេចក្តីសំរេចចិត្ត

២- កត់សំគាល់ អនុលោមតាមមាត្រា ៣៤ នៃអនុសញ្ញាថា អនុសញ្ញាត្រូវបើកអោយចុះហត្ថលេខានៅទីស្នាក់ការកណ្តាលអង្គការសុខភាពពិភពលោកនៅទីក្រុងហ្សឺណែវ ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៣ និងបន្ទាប់មកនៅទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ ។

៣- អំពាវនាវដល់រដ្ឋ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ទាំងអស់ ដែលមានសិទ្ធិពិចារណាអំពីការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការយល់ព្រម ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការស្ម័គ្រចិត្តចូលជាសមាជិកនៃអនុសញ្ញានៅពេលឆាប់ៗបំផុតជាមួយនឹងទស្សនៈថា នឹងធ្វើអោយអនុសញ្ញាចូលជាធរមានក្នុងពេលឆាប់ៗដែលអាចធ្វើទៅបាន។

៤- តឿនដល់អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់និងរដ្ឋទាំងអស់ ដែលព្យួរការចូលជាធរមានរបស់អនុសញ្ញាអោយចាត់វិធានការសមស្រប ដើម្បីនឹងទប់ការប្រើប្រាស់ថ្នាំជក់ និងការរងផ្សែងថ្នាំជក់។

៥- កោះប្រជុំនូវរដ្ឋជាសមាជិកនៃអង្គការសុខភាពពិភពលោក ដែលជាអ្នកសង្កេតការណ៍ និងភាគី ដែលយកចិត្តទុកដាក់ដទៃទៀតអោយជួយឧបត្ថម្ភគាំទ្រសកម្មភាពត្រៀម ដែលមានយោងនៅក្នុងសេចក្តីសំរេចចិត្តនេះ ហើយនិងលើកទឹកចិត្ត ដោយមានប្រសិទ្ធភាពនូវការចូលជាធរមាន និងការអនុវត្តន៍យ៉ាងឆាប់បំផុតនៃអនុសញ្ញា។

៦- អំពាវនាវដល់អង្គការសហប្រជាជាតិ និងអញ្ជើញអង្គការអន្តរជាតិពាក់ព័ន្ធដទៃទៀតអោយបន្តការផ្តល់ ការឧបត្ថម្ភគាំទ្រដើម្បីពង្រឹងកម្មវិធីជាតិ និងអន្តរជាតិក្នុងការត្រួតពិនិត្យថ្នាំជក់។

៧- សំរេចបង្កើតអនុលោមទៅតាមវិធានលេខ៤២ នៃបទបញ្ជាផ្ទៃក្នុងរបស់មហាសន្និបាតស្តីពីសុខភាពពិភពលោក ក្រុមការងារអន្តររដ្ឋាភិបាល ដែលត្រូវបើកជូនអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់និងរដ្ឋទាំងអស់ ដូចមានយោងក្នុង មាត្រា ៣៤ នៃអនុសញ្ញា ដើម្បីនឹងពិចារណា និងរៀបចំការស្នើចំពោះបញ្ហាទាំងឡាយដូចមានកំណត់ក្នុងអនុសញ្ញា ដើម្បី ធ្វើការពិចារណានិងអនុម័ត តាមការសមស្របនៅកិច្ចប្រជុំលើកទី ១ នៃសន្និសីទភាគី។ បញ្ហាទាំងនោះមាន :

១- បទបញ្ជាផ្ទៃក្នុងសំរាប់សន្និសីទភាគី ( មាត្រា ២៣.៣) រួមទាំងលក្ខណៈវិនិច្ឆ័យសំរាប់ការចូលរួមនៃអ្នក សង្កេតការណ៍ក្នុងកិច្ចប្រជុំសន្និសីទភាគី ( មាត្រា ៣៣.៦)

២- ជម្រើសសំរាប់ការតែងតាំងលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងការសម្របសម្រួលសំរាប់ការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋាន( មាត្រា ២៤.១)

៣- វិធានហិរញ្ញវត្ថុសំរាប់សន្និសីទភាគី និងអង្គការរណបរបស់វា និងបញ្ញត្តិហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រង ការ ប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ( មាត្រា ២៣.៤)

៤- គម្រោងថវិកាសំរាប់ការបរិច្ឆេទហិរញ្ញវត្ថុលើកទី ១ ( មាត្រា ២៣.៤)

៥- ការពិនិត្យឡើងវិញនូវប្រភពដែលមានស្រាប់ និងសក្តានុភូត និងយន្តការផ្តល់ជំនួយដល់ភាគី ដើម្បី បំពេញនូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញា ( មាត្រា ២៦.៥) ។

៨- សំរេចតទៅទៀតថា ក្រុមការងារអន្តររដ្ឋាភិបាល ដែលអាចផ្លាស់ប្តូរបាន ក៏ត្រូវត្រួតមើលដែរនូវការរៀបចំ កិច្ចប្រជុំទីមួយនៃសន្និសីទភាគី និងធ្វើរបាយការណ៍ផ្ទាល់ទៅសន្និសីទ។

៩- សំរេចចិត្តថា សេចក្តីសំរេចដែលបានធ្វើដោយអង្គការអន្តររដ្ឋាភិបាលសំរាប់ការចរចាស្តីពីអនុសញ្ញាគោលនៃ អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ ពាក់ព័ន្ធដល់ការចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែជា សកម្មភាពរបស់ក្រុមការងារអន្តររដ្ឋាភិបាល។

១០- ស្នើដល់អគ្គនាយក :

១- អោយផ្តល់នូវការងារលេខាធិការដ្ឋាននៅក្រោមអនុសញ្ញារហូតទៅដល់ពេលមានអគ្គលេខាធិការដ្ឋាន អចិន្ត្រៃយ៍មួយត្រូវបានតែងតាំង និងបង្កើតឡើង

២- រៀបចំដំណាក់កាលសមស្របដើម្បីផ្តល់ការឧបត្ថម្ភគាំទ្រដល់រដ្ឋជាសមាជិក ជាពិសេសប្រទេសកំពុង អភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចក្នុងអន្តរភាព ក្នុងការរៀបចំដើម្បីដាក់អនុសញ្ញាអោយចូលជា ធរមាន

៣- ត្រូវកោះប្រជុំក្រុមការងារអន្តររដ្ឋាភិបាលជាញឹកញាប់ទៅតាមការចាំបាច់ក្នុងចន្លោះពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ និងថ្ងៃប្រជុំលើក ទី១ នៃសន្និសីទភាគី

៤- បន្តធានាថា អង្គការសុខភាពពិភពលោកនិងដើរតួនាទីគន្លឹះក្នុងការផ្តល់យោបល់បច្ចេកទេស ការដឹកនាំ និងការឧបត្ថម្ភគាំទ្រការត្រួតពិនិត្យថ្នាំជក់ជាសកល

៥- បន្តអោយមហាសន្និបាតស្តីពីសុខភាពទទួលបាននូវព័ត៌មានស្តីពីការជឿនលឿន ពីការចូលជាធរមាននៃអនុសញ្ញា និងពីការរៀបចំដែលកំពុងមានដំណើរការសំរាប់កិច្ចប្រជុំលើកទី ១ នៃសន្និសីទភាគី ។

# ឧបសម្ព័ន្ធទី ២

## ប្រវត្តិនៃដំណើរការរបស់អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់

គំនិតរបស់លិខិតូបករណ៍អន្តរជាតិសំរាប់ថ្នាំជក់មួយ ត្រូវបានផ្តួចផ្តើមជាមួយនឹងការអនុម័តសេចក្តីសំរេចចិត្ត WHA ៤៨.១១ នៅខែឧសភា ឆ្នាំ ១៩៩៥ សំណូមពរអោយអគ្គនាយក ធ្វើរបាយការណ៍ជូនកិច្ចប្រជុំទី ៤៩ នៃមហាសន្និបាតសុខភាពពិភពលោក ស្តីពីការអាចធ្វើបាននៃការអភិវឌ្ឍន៍លិខិតូបករណ៍អន្តរជាតិមួយទុកជាសេចក្តីណែនាំ ការប្រកាស ឬអនុសញ្ញាអន្តរជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់មួយ។

ជាលទ្ធផលនៃសេចក្តីសំរេចចិត្ត WHA 48.11 អង្គការសុខភាពពិភពលោកត្រូវបានគេស្នើសុំអោយធ្វើសេចក្តីព្រាង នៃការសិក្សាលើការអាចធ្វើបាន ដែលលោកអគ្គនាយកត្រូវបង្ហាញជូនទៅកិច្ចប្រជុំទី ៩៧ នៃក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការសុខភាពពិភពលោក ("ការអាចធ្វើបានរបស់លិខិតូបករណ៍អន្តរជាតិមួយសំរាប់ការត្រួតពិនិត្យថ្នាំជក់" [IB97/INS.DOC.4]) នៅក្នុងរយៈនៃកិច្ចប្រជុំដដែលនោះ ក្រុមប្រឹក្សាប្រតិបត្តិបានអនុម័តសេចក្តីសំរេចចិត្ត IB97.R8 "អនុសញ្ញាក្របខ័ណ្ឌអន្តរជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់" បន្ទាប់មកនៅឆ្នាំដដែលនោះកិច្ចប្រជុំទី ៤៩ នៃ WHA បានអនុម័តសេចក្តីសំរេចចិត្ត WHA .49.17 "អនុសញ្ញាគោលអន្តរជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់" ស្នើសុំអោយអគ្គនាយកផ្តួចផ្តើមធ្វើការអភិវឌ្ឍន៍នូវអនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់។ ជាលទ្ធផលនៃសេចក្តីសំរេចចិត្តនោះ ការរៀបចំធ្វើសន្និសញ្ញាលើកទី ១ របស់អង្គការសុខភាពពិភពលោក ត្រូវបានប្រកាសជាផ្លូវការ ។

នៅឆ្នាំ១៩៩៨ អគ្គនាយកអង្គការសុខភាពពិភពលោក ដែលទើបនឹងជាប់ឆ្នោតថ្មី គឺលោកវេជ្ជបណ្ឌិត Gro Harlem Brundtland បានចាត់ទុកការត្រួតពិនិត្យថ្នាំជក់ជាសកលជាអាទិភាពមួយ តាមរយៈការបង្កើតនូវខុទ្ទកាល័យគម្រោងមួយឈ្មោះថា សេចក្តីផ្តួចផ្តើមនៃការគ្មានថ្នាំជក់ ដើម្បីផ្តោតទៅលើការផ្តោតអារម្មណ៍អន្តរជាតិ ធនធាន និងសកម្មភាព ចំពោះការរីករាលដាលថ្នាំជក់ពិតប្រាកដ។ ភាពជាដៃគូពហុវិស័យថ្មីដែលឆ្លុះបញ្ចាំងនូវលក្ខណៈរបស់សកម្មភាពត្រូវបានអភិវឌ្ឍឡើង។ សំខាន់ជាងនេះទៅទៀត លោកវេជ្ជបណ្ឌិត Brundtland បានធ្វើការជាមួយរដ្ឋជាសមាជិកដើម្បីធានានូវអាណត្តិនៃការចរចាសំរាប់អនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់ ហើយរៀបចំនូវការងារសំរាប់បញ្ចុះបញ្ចូលសាធារណជន និងមតិនយោបាយ ក្នុងការគាំទ្រនូវវិធានត្រួតពិនិត្យថ្នាំជក់ជាសកល។

នៅខែឧសភា ឆ្នាំ១៩៩៩ មហាសន្និបាតសុខភាពពិភពលោកលើកទី ៥២ បានត្រួសត្រាយផ្លូវសំរាប់ការចរចាពហុភាគីអំពីអនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់ នៃអង្គការសុខភាពពិភពលោក ហើយនិងពិធីសារពាក់ព័ន្ធដែលអាចមាន។ សេចក្តីសំរេចចិត្ត WHA ៥២.១៨ បានបង្កើតអង្គភាព ២ ដើម្បីធ្វើសេចក្តីព្រាងអនុសញ្ញាគោលបញ្ចប់ការចរចា និងដាក់ជូននូវអត្ថបទចុងក្រោយបង្ហស់ជូនមហាសន្និបាតសុខភាពពិភពលោក ទី ៥៦ ដើម្បីធ្វើការពិចារណា។ អង្គភាពទាំង ២ នោះរួមមាន ក្រុមការងារបច្ចេកទេសមួយដើម្បីរៀបចំសំណើសមាសធាតុសំរាប់ក្របខ័ណ្ឌអនុសញ្ញា និងអង្គភាពអន្តររដ្ឋាភិបាល ដើម្បីការចរចាសំរាប់ធ្វើសេចក្តីព្រាង និងចរចាសំណើអនុសញ្ញាគោល និងពិធីសារពាក់ព័ន្ធដែលអាចមាន។

អង្គភាពទាំងពីរត្រូវបានបើកជូនរដ្ឋជាសមាជិក និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលរដ្ឋជាសមាជិករបស់ខ្លួន បានផ្ទេរសមត្ថកិច្ចពាក់ព័ន្ធដល់ការត្រួតពិនិត្យថ្នាំជក់មកអោយខ្លួន។

ក្រុមការងារបានរៀបចំកិច្ចប្រជុំពីរនៅទីក្រុងហ្សឺណែវ (២៦-២៩ ខែតុលា ឆ្នាំ១៩៩៩ និង២៧-២៩ ខែមីនា ឆ្នាំ២000) លទ្ធផលរបស់វាគឺជាឯកសារមួយ ដែលមានអត្ថបទរបស់សេចក្តីស្នើសមាសធាតុសំរាប់អនុសញ្ញាគោល ដែលបានដាក់ជូនទៅមហាសន្និបាតសុខភាពពិភពលោកទី ៥៣ ជាមួយនិងអនុសាសន៍របស់ក្រុមការងារ។ នៅក្នុងសេចក្តីសំរេច WHA 53:6 មហាសន្និបាតសុខភាពបានអំពាវនាវអោយអង្គការអន្តរដ្ឋាភិបាលដើម្បីការចរចា ចាប់ផ្តើមធ្វើការចរចាដោយមាន និងការផ្តោតអារម្មណ៍ជាបឋមទៅលើសេចក្តីព្រាងអនុសញ្ញាគោល ដោយគ្មានការប៉ះពាល់ខូចខាតដល់ការពិភាក្សាទៅអនាគតលើពិភាក្សាដែលអាចមានដើម្បីធ្វើរបាយការណ៍អំពីការជឿនលឿនទៅជូនមហាសន្និបាត សុខភាពពិភពលោកលើកទី៥៤ និងពិនិត្យបញ្ហាស្តីពីការពង្រីកនូវការចូលរួមដោយអង្គការមិនមែនរដ្ឋាភិបាលជា អ្នកសង្កេតការណ៍។

កិច្ចប្រជុំលើកទី ១ នៃអង្គការអន្តររដ្ឋាភិបាលដើម្បីកិច្ចចរចា (ទីក្រុងហ្សឺណែវថ្ងៃទី ១៦-២១ ខែតុលា ឆ្នាំ២០០២) បានប្រារព្ធឡើងបន្ទាប់ពីមានការពិគ្រោះយោបល់ជាសាធារណៈ លើបញ្ហាពាក់ព័ន្ធជុំវិញអនុសញ្ញាគោល។ អគ្គនាយកបានកោះប្រជុំពិគ្រោះយោបល់ ក្នុងគោលបំណងផ្តល់នូវវេទិកាមួយសំរាប់សហគមន៍សុខភាពសាធារណៈ ឧស្សាហកម្មថ្នាំជក់ និងក្រុមកសិករក៏លើកឡើងអំពីករណីរបស់ខ្លួន។ កំណត់ហេតុនៃកិច្ចពិគ្រោះយោបល់អាចរកបាននៅអង្គការដើម្បីការចរចា ហើយតាមរយៈវែបសាយអង្គការសុខភាពពិភពលោកវែបសាយជូនដល់សាធារណជន ។ នៅកិច្ចប្រជុំទី១ លោកឯកអគ្គរដ្ឋទូត Celso Amorin នៃប្រទេសប្រេស៊ីលត្រូវបានជ្រើសតាំងជាប្រធាន ហើយការិយាល័យមួយត្រូវបានបង្កើតឡើង ដោយមានអនុប្រធានមកពីប្រទេសអូស្ត្រាលី ឥណ្ឌា សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ អាហ្វ្រិកខាង-ត្បូង ទួរគី និងសហរដ្ឋអាមេរិក។ អត្ថបទនៃសំណើសេចក្តីព្រាងវត្ថុធាតុសំរាប់អនុសញ្ញាអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលរៀបចំដោយក្រុមការងារ ត្រូវបានទទួលស្គាល់ថាជាមូលដ្ឋានដ៏សំខាន់សំរាប់ផ្តួចផ្តើមការចរចា បន្ទាប់មកលោកអគ្គរដ្ឋទូត Amorin បានរៀបចំអត្ថបទរបស់ប្រធានមួយសំរាប់អនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់។ សេចក្តីព្រាងលើកទី ១ នេះ ត្រូវបានបង្ហាញនៅខែមករា ឆ្នាំ២០០១ ទុកជាមូលដ្ឋានសំរាប់ការចរចាទៅអនាគតនៅកិច្ចប្រជុំលើកទី ២។ របាយការណ៍មួយស្តីពីការចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការងាររបស់អង្គការដើម្បីការចរចា ត្រូវបានបង្ហាញជូនក្រុមប្រឹក្សាប្រតិបត្តិនៅកិច្ចប្រជុំទី ១០៧ ខែមករា ឆ្នាំ២០០១ ។ អនុលោមតាមបញ្ញត្តិនៃសេចក្តីសំរេច IB107 (២) នៃក្រុមប្រឹក្សាប្រតិបត្តិ ប្រធាននៃក្រុមប្រឹក្សាដឹកនាំការងារជាមួយនឹងលោកប្រធានគណៈ-កម្មការអចិន្ត្រៃយ៍នៃអង្គការមិនមែនរដ្ឋាភិបាល បានបញ្ចូលអង្គការមិនមែនរដ្ឋាភិបាល ២ គឺ សហព័ន្ធពលកម្មអន្តរជាតិមិនមែនរដ្ឋាភិបាលប្រឆាំងនឹងថ្នាំជក់ និង Infact នៅក្នុងការទំនាក់ទំនងជាផ្លូវការជាមួយនិងអង្គការសុខភាពពិភពលោកនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ។

ក្នុងការរៀបចំសំរាប់កិច្ចប្រជុំលើកទី ២ នៃអង្គការដើម្បីការចរចា ការពិគ្រោះយោបល់អន្តរកិច្ចប្រជុំថ្នាក់តំបន់ត្រូវបានកោះប្រជុំនៅក្នុងតំបន់ និងអនុតំបន់ភាគច្រើន។ ការពិគ្រោះយោបល់អន្តរកិច្ចប្រជុំថ្នាក់តំបន់ និងអនុតំបន់បន្ថែមទៀត ត្រូវបានធ្វើដើម្បីការរៀបចំសំរាប់កិច្ចប្រជុំនីមួយៗ បន្ទាប់មកទៀតដើម្បីការចរចា។

នៅកិច្ចប្រជុំទី ២ នៃអង្គការដើម្បីចរចា (ទីក្រុងហ្សឺណែវ ថ្ងៃទី៣០ ខែមេសា- ៩ ខែឧសភា ឆ្នាំ២០០១) ការទទួលខុសត្រូវក្នុងការពិចារណាលើសំណើសេចក្តីព្រាងសមាសធាតុ ត្រូវបានចែកគ្នារវាងក្រុមការងារ ៣ ។ លទ្ធផលសំខាន់ គឺការផលិតនូវឯកសារការងារនៃសហប្រធានទាំង ៣ បញ្ជីនៃអត្ថបទសំណើដែលបានធ្វើនៅក្នុងកិច្ចប្រជុំ ត្រូវបានបញ្ចូលជាមួយនឹងអត្ថបទដើមរបស់ប្រធាន។ ឯកសារការងារនោះ ក្លាយទៅជាសេចក្តីព្រាងអត្ថបទបម្រុងរបស់ក្របខ័ណ្ឌអនុសញ្ញាគោល។

នៅកិច្ចប្រជុំទី ៣ (ទីក្រុងហ្សឺណែវ ថ្ងៃទី២២-២៨ ខែវិច្ឆិកា ឆ្នាំ២០០១) ក្រុមការងារ ២ បានចេញនូវអត្ថបទដែលបានពិនិត្យឡើងវិញ ហើយក្រោយមកក្រុមការងារទី ១ បានធ្វើសេចក្តីព្រាងអត្ថបទ។ ឯកសារទាំងនោះ ត្រូវបានប្រើសំរាប់ការចរចានៅក្នុងកិច្ចប្រជុំលើកទី ៤ ។ ដោយបានកាន់តំណែងជាអ្នកតំណាងអចិន្ត្រៃយ៍របស់ប្រទេសប្រេស៊ីលនៅទីក្រុងហ្សឺណែវជំនួសឯកអគ្គរដ្ឋទូត Amorin លោកឯកអគ្គរដ្ឋទូត Seixas Correêa ត្រូវបានជ្រើសរើសជាប្រធាននៃអង្គការអន្តររដ្ឋាភិបាលដើម្បីការចរចា សំរាប់អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ នៅក្នុងកិច្ចប្រជុំទី ៤ (ទីក្រុងហ្សឺណែវ ថ្ងៃទី១៨-២៣ ខែមីនា ឆ្នាំ២០០២) ។

មានការព្រមព្រៀងគ្នាថា លោកឯកអគ្គរដ្ឋទូត Seixas Correêa គួរតែរៀបចំអត្ថបទរបស់ប្រធានថ្មីមួយ ដែលនឹងទៅជាមូលដ្ឋានសំរាប់ការចរចា ក្នុងកិច្ចប្រជុំទី ៥ នៃអង្គការដើម្បីការចរចា (ថ្ងៃទី១៤-២៥ ខែតុលា ឆ្នាំ២០០២) អត្ថបទត្រូវបានបញ្ចេញបង្ហាញនៅខែកក្កដា ឆ្នាំ២០០២។ សន្និបាតបច្ចេកទេសអន្តរជាតិស្តីពីការធ្វើពាណិជ្ជកម្មមិនស្របច្បាប់លើផលិតផលថ្នាំជក់ ត្រូវបានរៀបចំឡើងដោយសហរដ្ឋអាមេរិកនៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ នៅទីក្រុងញ៉ូវយ៉ក (ថ្ងៃទី៣០ខែកក្កដា ដល់ថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២) ។

កិច្ចប្រជុំចំនួន ៤ ដំបូងនៃអង្គការដើម្បីការចរចា បានពិចារណាទៅលើអត្ថបទជំនួសមួយចំនួន។ ការពិភាក្សារួមគ្នានៃកិច្ចប្រជុំទី ៥ បានបង្រួមនូវជម្រើសបង្ករអោយមានការចរចាគ្នាទៅលើប្រធានបទពាក់ព័ន្ធជាងពីមុន។ បន្ទាប់ពីការអានលើក ទី ១ ក្នុងប្រជុំពេញអង្គនូវអត្ថបទថ្មីរបស់ប្រធាន បញ្ហា ៦ ត្រូវបានលើកឡើងហើយធ្វើការពិភាក្សាក្នុងការប្រជុំក្រៅផ្លូវការ មួយចំនួន : ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយជំរុញ និងការឧបត្ថម្ភកម្មវិធី ធនធានហិរញ្ញវត្ថុ ការធ្វើជំនួញមិនស្របច្បាប់លើផលិតផលថ្នាំជក់ ការទទួលខុសត្រូវ និងការសងជម្ងឺចិត្ត ការវេចខ្ចប់ និងការបិទផ្លាក ហើយនិងការធ្វើជំនួញ និង សុខភាព។ ក្រុមការងារក្រៅផ្លូវការ ក៏បានធ្វើការពិភាក្សាលើបញ្ហាច្បាប់ ស្ថាប័ន និងនីតិវិធី ហើយនិងការប្រើនូវពាក្យ។ ការឈានទៅមុខយ៉ាងលឿនត្រូវបានធ្វើ ហើយកុងសង់ស៊ីសត្រូវបានកើតឡើងនៅក្នុងវិស័យមួយចំនួន។ ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំក្រៅផ្លូវការ និងការពិគ្រោះយោបល់អន្តរកិច្ចប្រជុំជំនួយសំរាប់ប្រតិភូផ្សេងៗ និងក្រុមគណៈប្រតិភូ លោកអគ្គរដ្ឋទូត Seixas Correêa បានចេញនូវអត្ថបទដែលបានពិនិត្យខាងលើរបស់ប្រធាននៃអនុសញ្ញាគោលស្តីពីការពិនិត្យថ្នាំជក់ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣។

កិច្ចប្រជុំទី ៦ និងទីបញ្ចប់ នៃអង្គការដើម្បីការចរចា ត្រូវបានប្រារព្ធធ្វើពីថ្ងៃទី ១៧ ខែកុម្ភៈ ដល់ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៣។ ការចរចាមានការតឹងតែង និងទូលំទូលាយ។ បញ្ហាពីរសំខាន់ គឺការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយជំរុញ និងការឧបត្ថម្ភកម្មវិធី និងធនធានហិរញ្ញវត្ថុ ត្រូវបានពិភាក្សានៅក្នុងក្រុមក្រៅផ្លូវការពីរ។ នៅក្នុងកិច្ចប្រជុំពេញអង្គចុងក្រោយបំផុត អង្គការដើម្បីចរចា បានយល់ព្រមបញ្ជូនអត្ថបទរបស់មហាសន្និបាតសុខភាពពិភពលោកលើកទី ៥៦ ដើម្បី

ពិចារណា និងអនុម័ត អនុលោមទៅតាមមាត្រា ១៩ នៃធម្មនុញ្ញ។ មានការព្រមព្រៀងគ្នាថា ការពិភាក្សាលើពិធីសារ គួរតែពន្យារពេលរហូតដល់កិច្ចប្រជុំមហាសន្និបាតសុខភាព ដែលជាពេលគួរតែពិចារណាទៅលើបញ្ហា។ នៅកិច្ចប្រជុំពេញអង្គចុងក្រោយបំផុត អង្គការដើម្បីការចរចាបានយល់ព្រមថា ប្រធាននៃអង្គការដើម្បីការចរចា គួរតែព្រាងសេចក្តីសំរេចចិត្តមួយ ផ្តល់អនុសាសន៍អោយអនុម័តអនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ ដោយមហាសន្និបាតសុខភាព។ ដូច្នេះ សេចក្តីព្រាងចុងក្រោយបង្អស់នៃអនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់ ត្រូវបានដាក់ជូនមហាសន្និបាតសុខភាព ដើម្បីពិចារណា និងអនុម័ត អនុលោមតាមសេចក្តីសំរេចចិត្ត WHA 52.18 ។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ មហាសន្និបាតសុខភាពពិភពលោកលើកទី ៥៦ បានអនុម័តជាឯកច្ឆ័ន្ទនូវអនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់។ អនុសញ្ញាត្រូវបានបើកអោយចុះហត្ថលេខាសំរាប់រយៈពេល ១ ឆ្នាំ ចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ ទៅ ២៣ ខែមិថុនា ឆ្នាំ២០០៣ នៅទីស្នាក់ការកណ្តាលនៃអង្គការសុខភាពពិភពលោកនៅទីក្រុងហ្សឺណែវ និងបន្ទាប់មកនៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញ៉ូវយ៉ក ចាប់ពីថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣ ទៅ ២៩ ខែមិថុនា ឆ្នាំ២០០៤។

ក្របខ័ណ្ឌអនុសញ្ញាគោលនៃអង្គការសុខភាពពិភលោកស្តីពីការត្រួតពិនិត្យថ្នាំជក់

ជាសញ្ញាសំគាល់មួយសំរាប់អនាគតរបស់សុខភាពសាធារណៈជាសកល ហើយមានការជំពាក់ទាក់ទងជាមួយនិងគោលបំណងសុខភាពនៃអង្គការសុខភាពពិភពលោក។ ទីបញ្ចប់នៃដំណើរការចរចា និងការអនុម័តជាឯកច្ឆ័ន្ទនៃអនុសញ្ញាគោលស្តីពីការត្រួតពិនិត្យថ្នាំជក់ ដោយស្របទាំងស្រុងជាមួយនឹងសេចក្តីសំរេចចិត្តរបស់មហាសន្និបាតសុខភាពពិភពលោកជាគោលសំរាប់ការផ្សព្វផ្សាយជំរុញសុខភាពសាធារណៈ និងផ្តល់នូវទិដ្ឋភាពច្បាប់ថ្មីសំរាប់សហប្រតិបត្តិការអន្តរជាតិ ដើម្បីសុខភាព។

១- ឯកសារ A 53/12ក

២- ឯកសារ A/FCTC/INB1/2

៣- ឯកសារ A/FCTC/INB2/2

៤- ឯកសារ EB107/19

៥- ឯកសារ A/FCTC/INB2/6 Add.1

៦- សេចក្តីព្រាងសេចក្តីសំរេចចិត្តនេះមាននៅក្នុងឯកសារ A56/8/REV.1

៧- សូមមើលឯកសារ A56/8 ឧបសម្ព័ន្ធ

៨- ឯកសារអង្គការសុខភាពពិភពលោក WHA56.1

## ឧបសម្ព័ន្ធទី ៣

## និយមន័យនៃពាក្យសំខាន់ៗ ក្នុងគំរោងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់

១-កម្មន្តសាល :រោងចក្រសំរាប់ផលិតផលស្រាល១

២-យុត្តាធិការ :ប្រព័ន្ធតុលាការ "សមត្ថកិច្ចរបស់តុលាការ"

៣-អត្តបដិរូប :សញ្ញាសំគាល់សំរាប់ក្រុមហ៊ុនណាមួយ

៤- ហានិភ័យ : អ្វីដែលកើតមាននាំអោយភាពមហន្តរាយ

៥- គតិយុត្ត : អ្វីជាច្បាប់ ស្របច្បាប់

៦- យុត្តិសាស្ត្រ : សាលក្រមតុលាការ

៧- អង្គការរណប : អង្គការដែលនៅក្រោមអង្គការណាមួយទៀតដែលអង្គការមួយជាអ្នកបង្កើត

៨- អន្តរភាព :ភាពដែលមិនទាន់ពេញលេញនៅឡើយ

៩- សន្ធានកម្ម : អ្នកសំរបសំរួល

១០- យថាភូត : អ្វីដែលគេឱ្យយើងធ្វើតាមគេមានគំរូតែម្តង "ស្របច្បាប់តែម្តងហើយគេទទួលស្គាល់"

១១- លិខិតរូបករណ៍ : លិខិតសរសេរសំរាប់ដឹកលំ សំរាប់អន្តរជាតិ

១២-ក្របខ័ណ្ឌ : បន្ទាក់ក្រឡាត្នា

១៣- បរិស្ថានគតិយុត្ត : ជំរុញច្បាប់ដែលមាន

១៤- អនីតិជន : ជនមិនទាន់គ្រប់អាយុ

១៥- ម៉ាស៊ីនលក់ថ្នាំជក់ :ម៉ាស៊ីនលក់បារីអ្នកណាទិញក៏បាន

១៦- ការឧបត្ថម្ភចំពោះសកម្មជំនួសដែលអាចធ្វើឱ្យរស់បាន : ជារបរមួយដើម្បីជំនួសការដាំថ្នាំជក់ដែលអាចរស់បាន

១៧- សូចនាករ : អ្វីដែលជារង្វាស់ដើម្បីបានលទ្ធផលប៉ុណ្ណា

១៨- សន្និសិទ្ធភាគី :ការប្រជុំរបស់សមាជិក "ប្រទេសដែលជាសមាជិកភាគី"

១៩- សក្តានុភូត : អ្វីដែលមានសំរាប់រុញច្រានឱ្យទៅមុខ

២០- ការនិយមជាសាកល : អ្វីដែលពិភពលោកត្រូវការហើយដែលជាទូទៅ "អ្វីៗដែលគេនិយមគ្រប់ៗគ្នា"

<u>ឯកសារយោង</u> :

- វចនានុក្រមច្បាប់
- FCTC English

World Health Organization
Geneva, Switzerland

# WHO FRAMEWORK CONVENTION ON TOBACCO CONTROL

World Health Organization

2003

WHO Library Cataloguing-in-Publication Data

WHO Framework Convention on Tobacco Control.

1.Tobacco - supply and distribution 2.Tobacco industry - legislation 3.Tobacco smoke pollution - prevention and control 4.Tobacco use cessation 5.Treaties I.World Health Organization.

ISBN 92 4 159101 3 (LC/NLM classification: HD 9130.6)

**© World Health Organization 2003, updated reprint 2004**

All rights reserved. Publications of the World Health Organization can be obtained from Marketing and Dissemination, World Health Organization, 20 Avenue Appia, 1211 Geneva 27, Switzerland (tel: +41 22 791 2476; fax: +41 22 791 4857; email: bookorders@who.int). Requests for permission to reproduce or translate WHO publications – whether for sale or for noncommercial distribution – should be addressed to Publications, at the above address (fax: +41 22 791 4806; email: permissions@who.int).

The designations employed and the presentation of the material in this publication do not imply the expression of any opinion whatsoever on the part of the World Health Organization concerning the legal status of any country, territory, city or area or of its authorities, or concerning the delimitation of its frontiers or boundaries. Dotted lines on maps represent approximate border lines for which there may not yet be full agreement.

The mention of specific companies or of certain manufacturers' products does not imply that they are endorsed or recommended by the World Health Organization in preference to others of a similar nature that are not mentioned. Errors and omissions excepted, the names of proprietary products are distinguished by initial capital letters.

The World Health Organization does not warrant that the information contained in this publication is complete and correct and shall not be liable for any damages incurred as a result of its use.

Printed in World Health Organization, Geneva.

# Table of Contents


**Foreword** ..... v

**WHO FCTC text** ..... 1

Preamble ..... 1

| | | |
|---|---|---|
| **Part I:** | **Introduction** | 4 |
| Article 1 | Use of terms | 4 |
| Article 2 | Relationship between this Convention and other agreements and legal instruments | 5 |
| **Part II:** | **Objective, guiding principles and general obligations** | 5 |
| Article 3 | Objective | 5 |
| Article 4 | Guiding Principles | 5 |
| Article 5 | General Obligations | 7 |
| **Part III:** | **Measures relating to the reduction of demand for tobacco** | 7 |
| Article 6 | Price and tax measures to reduce the demand for tobacco | 7 |
| Article 7 | Non-price measures to reduce the demand for tobacco | 8 |
| Article 8 | Protection from exposure to tobacco smoke | 8 |
| Article 9 | Regulation of the contents of tobacco products | 9 |
| Article 10 | Regulation of tobacco product disclosures | 9 |
| Article 11 | Packaging and labelling of tobacco products | 9 |
| Article 12 | Education, communication, training and public awareness | 10 |
| Article 13 | Tobacco advertising, promotion and sponsorship | 11 |
| Article 14 | Demand reduction measures concerning tobacco dependence and cessation | 13 |
| **Part IV:** | **Measures relating to the reduction of the supply of tobacco** | 13 |
| Article 15 | Illicit trade in tobacco products | 13 |
| Article 16 | Sales to and by minors | 15 |
| Article 17 | Provision of support for economically viable alternative activities | 16 |
| **Part V:** | **Protection of the environment** | 16 |
| Article 18 | Protection of the environment and the health of persons | 16 |
| **Part VI:** | **Questions related to liability** | 17 |
| Article 19 | Liability | 17 |
| **Part VII:** | **Scientific and technical cooperation and communication of information** | 17 |
| Article 20 | Research, surveillance and exchange of information | 17 |
| Article 21 | Reporting and exchange of information | 19 |
| Article 22 | Cooperation in the scientific, technical and legal fields and provision of related expertise | 20 |
| **Part VIII:** | **Institutional arrangements and financial resources** | 21 |
| Article 23 | Conference of the Parties | 21 |
| Article 24 | Secretariat | 22 |

Article 25 Relations between the Conference of the Parties and intergovernmental organizations ..... 23
Article 26 Financial resources ..... 23
**Part IX: Settlement of disputes ..... 24**
Article 27 Settlement of disputes ..... 24
**Part X: Development of the convention ..... 25**
Article 28 Amendments to this Convention ..... 25
Article 29 Adoption and amendment of annexes to this Convention ..... 26
**Part XI: Final Provisions ..... 26**
Article 30 Reservations ..... 26
Article 31 Withdrawal ..... 26
Article 32 Right to vote ..... 27
Article 33 Protocols ..... 27
Article 34 Signature ..... 27
Article 35 Ratification, acceptance, approval, formal confirmation or accession ..... 28
Article 36 Entry into force ..... 28
Article 37 Depositary ..... 29
Article 38 Authentic texts ..... 29
**Annex 1: WHA Resolution 56.1 – WHO Framework Convention on Tobacco Control ..... 30**
**Annex 2: History of the FCTC process ..... 33**

# FOREWORD

